យង្កិញ្ចិ កុសលកម្មំ, កត្តព្វំ កិរិយំ មម, កាយេន វាចាមនសា, តិទសេ សុគតំ កតំ, យេ សត្តា សញ្ញិនោ អត្ថិ, យេ ច សត្តា អសញ្ញិនោ, កតំ បុញ្ញផលំ មយ្ហំ, សព្វេ ភាគី ភវន្តុ តេ, យេ តំ កតំ សុវេទិសុ, ទិន្នំ បុញ្ញផលំ មយា, យេ ច តត្ថ ន ជានន្តិ, ទេវា គន្ត្វា និវេទយុំ, សព្វេ លោកម្ហិ យេ សត្តា, ជីវន្តាហារហេតុកា, មនុញ្ញំ ភោជនំ សព្វេ, លភន្តុ មម ចេតសាតិ ។

## យំកិញ្ចិប្រែ ពាក្យកាព្យ

កុសលកម្មឯណា ដែលជាការឥតសៅហ្មង
យើងខ្ញុំបានកសាង ដោយកាយវាចាចិត្ត ។
កុសលទាំងអស់នោះ អាចជួយដោះជួយបង្ខិត
នាំសត្វឱ្យជាប់ចិត្ត ឋិតនៅនាស្ថានឧត្តម ។
សត្វដែលមានសញ្ញា ទេវតាមនុស្សឬព្រហ្ម
ដែលមានសក្តិតូចធំ ព្រមទាំងសត្វឥតសញ្ញា ។
ឱ្យបានចំណែកផល ដែលជាគុណដ៏ថ្លៃថ្លា
យើងខ្ញុំបានរចនា ចាត់ចែងការកុសលហ្នឹង ។
ម៉្យាងទៀតសត្វឯណា ឆ្ងាយអស្ចារ្យពុំបានដឹង
សូមទេវតាទៅប្តឹង ជាដំណឹងយ៉ាងនេះថា ។
រីជនឈ្មោះឯណោះ ស្រីឬប្រុសបានជ្រះថ្លា
កសាងបុណ្យកិរិយា វត្តជាផ្លូវឆើតឆាយ ។
ហើយគេឧទ្ទិសផល ឱ្យបានដល់អ្នកទាំងឡាយ
ចូរមានចិត្តស្រស់ស្រាយ បន្ទន់កាយទទួលយក ។

| | |
|---|---|
| សត្វលោកទាំងអស់នោះ | ដែលបានរស់តរៀងមក |
| សូមឱ្យបានបរិភោគ | នូវអាហារទើបរស់បាន ។ |
| សត្វទាំងអស់នោះណា | បានសុខាគ្រប់ៗប្រាណ |
| អាហារយ៉ាងចំណាន | សូមឱ្យបានកុំខានឡើយ ។ |

## តេជះខ្ញុំសាង

| | | |
|---|---|---|
| តេជះខ្ញុំសាង | សម្អិតសម្អាង | ឱនកាយវាចា |
| សូមសុខសោភា | រួចពីទុក្ខា | ឆ្លងដល់ត្រើយមហា |
| | ពោលគឺនិព្វាន ។ | |
| គ្រប់ជាន់គ្រប់ជាតិ | កុំឱ្យខ្ញុំឃ្លាត | ពីសីលនិងទាន |
| គំនិតខ្ញុំកើត | កំណើតខ្ញុំមាន | មគ្គផលជាស្ពាន |
| | ដល់ស្ថានថ្លៃថ្លា ។ | |
| ខ្ញុំជូនមគ្គផល | ចំពោះទៅដល់ | មាតាបិតា |
| គុណគ្រូឧប- | ជ្ឈាយាចារ្យ | គុណញាតិកា |
| | ប្រាំពីរសន្តាន ។ | |
| ជីដូនជីតា | រស់នៅក្តីណា | លោកម្ចាស់ចែកឋាន |
| ខ្ញុំជូនមគ្គផល | កុសលថ្កើងថ្កាន | សូមសុខក្សេមក្សាន្ត |
| | ដល់ស្ថានផុតទុក្ខ ។ | |

# ឧទ្ទិសបទ

កុសលកម្មនេះយើងខ្ញុំសាង សម្អិតសម្អាងកាយវាចា
តម្រង់ចិត្តនូវមនសិការ ទៅតាមសាសនានៃព្រះពុទ្ធ ។
សូមអានិសង្សនៃធម្មទាន ទុំះប្រាកដមានជាឱសថ
ព្យាបាលរោគល្ងង់ដែលជាប់ជិត ក្នុងសន្តានចិត្តយើងរាល់គ្នា ។
បានជាពន្លឺការបដិបត្តិ ចិត្តប្រុងប្រយ័ត្នប្រឹងពុះពារ
សទ្ធាដ៏មាំនាំមាគ៌ា ទានសីលភាវនាជាកម្លាំង ។
សតិញ៉ាំងយើងមិនឱ្យភ្លេច នឹកគិតជានិច្ចអនិច្ចំ
កុសលអកុសលនូវទុក្ខំ រាគាមោហំអនត្តា ។
ឆន្ទៈវិរិយៈក្នុងបដិបត្តិ ចិត្តប្រឹងបំបាត់ភពកាមា
អវិជ្ជាទិដ្ឋាសាវ៉ា បញ្ញាខ្លាំងក្លាទើបកាត់អស់ ។
នឹងបានសម្រេចដល់និញ្វាន ទីឋានដែលគ្មានទុក្ខសោកសោះ
តណ្ហាសង្ខាររលត់អស់ អាល័យសូន្យព្រោះវិបស្សនា ។
សូមអានិសង្សប្រពៃនេះ បានជាតម្រិះនូវប្រាជ្ញា
ជូនចំពោះមាតាបិតា គ្រូបាអាចារ្យសាលោហិត ។
ញាតិមិត្តបងប្អូនជីដូនតា ធ្វើកាលកិរិយាឬនៅស្ថិត
ទទួលផលយើងខ្ញុំនឹកគិត បានល្អប្រណីតឧទ្ទិសទៅ ។
សូមរួចផុតទុក្ខសោកភយា បានសុខនៅនាទីលំនៅ
ភ្លឺមានបញ្ញាងាករកផ្លូវ ដើម្បីឆ្លងទៅស្ថានឧត្តម ។
មនុស្សសួគ៌និញ្វានកុំបីខាន សូមសម្រេចបានបុណ្យសន្សំ
រួមនូវកុសលតេជះខ្ញុំ ឧទ្ទិសជូនផ្សំគ្រានេះផង ។
សូមឱ្យព្រះពុទ្ធសាសនា រុងរឿងអស្ចារ្យល្អកន្លង
គ្រប់៥ពាន់ឆ្នាំព្រះបំណង សត្វច្រើនបានឆ្លងវដ្តសង្សារ ។

សូមឱ្យមនុស្សលោកប្រាសហិង្សា បញ្ចប់នូវការបៀតបៀនគ្នា
រស់នៅដោយសុខមានធម្មា ប្រឹងសាងសទ្ធាក្នុងព្រះពុទ្ធ។
ពុទ្ធបរិស័ទដែលស្ថិតនៅ សង្ឃាតតាមផ្លូវដ៏វិសុទ្ធិ
វិន័យព្រះពុទ្ធទ្រង់បញ្ញត្តិ សូមបានអនុវត្តប្រាកដឡើង ។
ទឹកដីបានសុខសន្តិល្អ មនុស្សសត្តនិករបានរុងរឿង
ព្រះសទ្ធម្មល្អបរិស័ទថ្កើង សន្តិភាពយើងប្រឹងឱ្យបាន ។
ព្រះពុទ្ធពរប្រាំជាកម្លាំង យើងខំរារាំងបាបគ្រប់ប្រាណ
សតិយើងមានកុំបីខាន បាបកម្មកុំមានឱកាសឡើយ ។
យុត្តិធម៌ចូលមានក្នុងសង្គម ក្តីសុខសុខុមដ៏ជាត្រើយ
សត្វលោករួចទោសទុក្ខភ័យស្បើយ អស់អាសវៈហើយនិព្វានហោង ។
យើងខ្ញុំប្រាថ្នាទៅគ្រប់ជាតិ កុំគប្បីឃ្លាតក្តីបំណង
ជួននឹងព្រះពុទ្ធធម៌សង្ឃផង ចិត្តប៉ុនប៉ងឆ្លងវដ្តសង្សារ ។
សូមបានបដិបត្តិនូវមេត្តា មានអភិញ្ញាញាណទស្សនា
សម្រេចនិព្វានដោយបញ្ញា វិមុត្តិសុខាជាតិចប់ហោង ៕

# ប្រកាសទេវតា (ពាក្យភាព្យ)

បពិត្រទេវតា សព្វស្ថានរក្សា សោឡសសួគ៌ា
គិរីបពិត សមុទ្ទគង្គា លោកបាល៤ណ៌
មូលមីរមេត្រី ។

នូវអស់រាល់គ្នា សូមលោកជួយជា បន្ទាល់សាក្សី
ជ្រោមជ្រែងក្រវើន ចម្រើនសួស្ដី បំពេញបារមី
នៃយើងសព្វថ្ងៃ ។

ដ្បិតយើងនេះណា សង្វាតឧស្សាហ៍ ពិតព្យាយាមនៃ
ផ្គងចិត្តហត្ថា វន្ទាប្រក្រតី សូមព្រះរត្នថ្លៃ
ទាំងបីឱ្យពរ ។

ព្រះពុទ្ធរក្សា ព្រះធម៌ធានា ព្រះសង្ឃសាទរ
ព្រះឥន្ទឱ្យជ័យ ព្រហ្មថ្លៃឱ្យពរ អស់ទេពនិករ
ជ្រោមជ្រែងរក្សា ។

ចម្រើនមគ្គផល ឱ្យបានរួចដល់ សម្បត្តិសួគ៌ា
ក្សេមក្សាន្តបានសុខ ផុតទុក្ខភយា បរិបូណ៌បញ្ញា
ដល់និព្វានហោង ៕

សាធុ... សាធុ... សាធុ...

# សុមង្គលគាថា ប្រែ

(ពាក្យពោលប្រកាសសុំសេចក្តីល្អ-សេចក្តីចម្រើនគ្រប់យ៉ាង)

| | |
|---|---|
| **ហោតុ សព្វំ សុមង្គលំ** | សុមង្គលគឺសេចក្តីចម្រើនដ៏ល្អគ្រប់យ៉ាងចូរមានដល់ខ្ញុំ |
| **រក្ខន្តុ សព្វទេវតា** | សូមទេវតាទាំងពួងទាំងឡាយបីបាច់រក្សានូវខ្ញុំ |
| **សព្វពុទ្ធានុភាវេន** | ដោយអានុភាពនៃព្រះពុទ្ធជាម្ចាស់គ្រប់ព្រះអង្គ |
| **សព្វធម្មានុភាវេន** | ដោយអានុភាពនៃព្រះធម៌ទាំងពួង |
| **សព្វសង្ឃានុភាវេន** | ដោយអានុភាពនៃព្រះសង្ឃទាំងពួង |
| **សោត្ថិ ហោតុ និរន្តរំ** | សូមសិរីសួស្តីជ័យមង្គលទាំងឡាយទាំងពួង |
| | ចូរមានដល់ខ្ញុំ ឱ្យបានសព្វកាលសព្វវេលា ៕ |

៤៧

## អារាធនាព្រះសង្ឃចម្រើនព្រះបរិត្ត

វិបត្តិប្បដិពាហាយ　　សព្វសម្បត្តិសិទ្ធិយា
សព្វទុក្ខវិនាសាយ　　បរិត្តំ ព្រូថ មង្គលំ ។
វិបត្តិប្បដិពាហាយ　　សព្វសម្បត្តិសិទ្ធិយា
សព្វភយវិនាសាយ　　បរិត្តំ ព្រូថ មង្គលំ ។
វិបត្តិប្បដិពាហាយ　　សព្វសម្បត្តិសិទ្ធិយា
សព្វរោគវិនាសាយ　　បរិត្តំ ព្រូថ មង្គលំ ។

### ពាក្យកាព្យ

(១) (សូមសម្តេចព្រះមហាសង្ឃរាជជាអម្ចាស់ និងព្រះសង្ឃទាំងឡាយ)

-(ឬ សូមលោកម្ចាស់ទាំងឡាយ)　　-សូមរីករាយដោយអនុគ្រោះ
សូត្របរិត្តដ៏ខ្ពង់ខ្ពស់　　ជាមង្គលដល់យើងខ្ញុំ
ដើម្បីការពារទោស　　ការកំហុសទាំងតូចធំ
ដែលមករួបរួមជុំ　　ជិតរូបអង្គនិងចិន្តា
ដើម្បីឱ្យសម្រេច　　នូវសម្បត្តិទាំងឡាយណា
ដែលយើងខ្ញុំប្រាថ្នា　　បានគ្រប់ប្រការកុំបីឃ្លាត
ដើម្បីវិនាសទៅ　　និងអស់នូវរោគាពាធ
ទុក្ខភយាជាតិ　　កុំបីបៀតយើងខ្ញុំបាន ។

---

១- បើសម្តេចព្រះមហាសង្ឃរាជ **ប្ួរ ត្រី** ស្តេចគង់ជាព្រះរាជាធិបតីក្នុងពិធីបុណ្យ ។

## ធម្មទេសនាយាចនគាថា

## ពាក្យសូមអារាធនាទេសនា

គ្រានោះសហម្បតី- ព្រហ្មជាឥស្សរលោកា
ចូលគាល់ព្រះសាស្ដា លើកហត្ថាសិរោរាប ។
ហើយពោលពាក្យទូលថា សូមករុណាស្ដេចទ្រង់ជ្រាប
ដ្បិតសត្វអន់ទន់ទាប ទុព្វលភាពបាបក្រៃក្រាស់ ។
ទន្ទឹងព្រះធម៌ថ្លៃ ជានិស្ស័យបច្ច័យច្បាស់
ឥឡូវទ្រង់បានត្រាស់ ត្រេកអរណាស់ពុំកន្ដើយ ។
សត្វខ្លះក្រាស់ដោយកាម មិនយល់តាមត្រៃលក្ខណ៍ឡើយ
ឥឡូវយល់ខ្លះហើយ ដោយអំណាចព្រះមានបុណ្យ ។
បើបានស្ដាប់ទេសនា បញ្ញាក្លាខ្លាំងលើសមុន
សូមព្រះដ៏មានបុណ្យ ទ្រង់និមន្តត្រាស់ទេសនា ។
ប្រោសសត្វបំបាត់សោក ទាំងរាគរោគរូបតណ្ហា
ងងឹតប្រែជ្រះថ្លា កើតបញ្ញាភិយ្យោយល់ ។
ត្រៃលោកគោកត្រៃលក្សណ៍ សង្សារចក្រវិលមិនដល់
អវិជ្ជាជាឫសគល់ ជាបច្ច័យនៃសង្ខារ ។
នាំសត្វឱ្យសោកសៅ លិចលង់នៅក្នុងសង្សារ
បញ្ចមារមោហន្ធការ រឹតរុំហ៊ុមជុំជាប់នៅ ។
ហេតុនោះសូមព្រះអង្គ ប្រោសស្រោចស្រង់ដាក់សំពៅ
ចម្លងសត្វឆ្ពោះទៅ ដាក់ត្រើយត្រាណនិព្វាននាយ ។
ដូចកល់ប្រទីបធំ សាយត្រសុំភ្លឺព្រោងព្រាយ
បំភ្លឺសត្វទាំងឡាយ ឱ្យសប្បាយក្សាន្តភិរម្យ ។
ព្រះសទ្ធម្មជាស្ពានជ័យ ព្រះវិន័យជារាងធំ

ព្រះសូត្រជាខ្សែរុំ ព្រះអភិធម្មជាស្បែកដាស ។
អរិយសច្ចជាអន្លូង សម្រាប់ទូងឱ្យឮច្បាស់
សត្វលោកងោកងុយណាស់ ឮស្គរដាស់ក្រោកឡើងបាន ។
បរិស័ទ ៤ ជំពូក ដូចផ្កាឈូកក្នុងជលដ្ឋាន
ខ្លះដុះចាំសូរ្យឆាន រះនឹងរីកដោយរស្មី ។
ព្រះធមិជាសូរ្យសែង រះឡើងចែងចាំងរង្សី
បំភ្លឺលោកទាំងបី ឱ្យយល់ផ្លូវឋានសុខា ៕

<u>បទព្រហ្មអារាធនាទេសនា ទី ១ ចប់</u>

## ពាក្យសូមអារាធនាទេសនា (២)

សហម្បតីព្រហ្ម ឱនបង្គំអារាធនា
សម្តេចព្រះភគវា ដោយគាថាយ៉ាងនេះឯង ។
ព្រះពុទ្ធទ្រង់អនុកូល ព្រមទទួលនឹងសម្តែង
ដោយតុណ្ហីភាពថ្លែង តាមភាវៈគុណករុណា ។
ទើបក្រោកចាកទីនោះ ភក្ត្រាឆ្ពោះព្រៃមិគទាយ៍
យាងចេញចរលីលា ពីទីនោះដោយព្រះបាទ ។
ញ៉ាំងសត្វចូលពុទ្ធចក្រ មានបញ្ចវគ្គីយ៍ជាអាទិ៍
ឱ្យផឹកអម្រឹតជាតិ រសនិព្វានតាមធម្មតា ។
ចាប់ដើមពីនោះឯង ទ្រង់សម្តែងធម៌ទេសនា
ធ្វើពុទ្ធក្រឹត្យា អស់វស្សាសែសិបប្រាំ ។
ពុំថយពុំបន្ធូរ ប្រយោជន៍យូរអង្វែងឆ្នាំ
សម្រេចបុញ្ញកម្ម ដល់សព្វសត្វទាំងភពត្រ័យ ។
ហេតុនោះឥឡូវនេះ យើងខ្ញុំនេះសាទរក្រៃ
បពិត្រព្រះគុណថ្លៃ សូមនិមន្តប្រោសទេសនា ។
អនុគ្រោះពួកបរិស័ទ ដែលជាប់ខាត់ដោយមោហា
ឱ្យកើតមានបញ្ញា ប្រាកដនាទីនេះហោង ៕

បទព្រហ្មអារាធនាទេសនា ទី ២ ចប់

## ពាក្យសូមអារាធនាទេសនា (៣)

វិព្រហ្មដ៏ជាធំ ក្រៃលែងព្រហ្មផងនានា
ទើបលុតព្រះជង្ឃា លើកហត្ថានមស្សការ ។
បពិត្រព្រះអង្គអើយ ព្រះគុណអើយសូមមេត្តា
ប្រោសសត្វមនុស្សទេវតា ទ្រង់ករុណាសម្តែងធម៌ ។
ដ្បិតសត្វទន្ទឹងណាស់ ឮព្រះត្រាស់ហើយត្រេកអរ
នឹងបានស្តាប់ព្រះធម៌ ហើយនឹងបានចេញចាកទុក្ខ ។
ដ្បិតសត្វផងនានា មានអវិជ្ជាពោលគឺលាមក
ដូចធូលីផង់ដីភក់ កករល្អក់ជាប់នេត្រា ។
ព្រោះហេតុមោហៈធំ ក៏រួបរុំជុំកាយា
បាត់បង់អប្បប្រាជ្ញា មិនឱ្យឃើញព្រះត្រៃលក្ខណ៍ ។
ងងឹតងងុលងប់ ឱ្យជ្រុលជ្រប់ដូចមនុស្សខ្វាក់
លលើហើយលលាក់ ដូចអន្ទាក់ឆ្វាក់រឹតក ។
នឹងរកអ្នកណាមួយ នឹងមកជួយស្រោយក៏ក្រ
មានតែព្រះសុធម៌ ទើបនឹងមកជួយស្រោយបាន ។
ហេតុនោះព្រះអង្គអើយ ព្រះគុណអើយសូមប្រោសប្រាណ
ដ្បិតព្រហ្មខ្ញុំរាប់អាន ចុះមកថ្កានអារាធនា ។
ព្រះធម៌ថ្លៃវិសេស លត់កិលេសនូវតណ្ហា
នាំចិត្តឱ្យជ្រះថ្លា សោមនស្សាឥតសៅហ្មង ។
ហេតុនោះព្រះអង្គអើយ ព្រះគុណអើយសូមចម្លង
នាំសត្វឱ្យបានឆ្លង ដាក់ដល់ត្រើយនិព្វាននាយ ៕

<u>បទព្រហ្មអារាធនាទេសនា ទី ៣ ចប់</u>

# នមោការដ្ឋកៈ ៨ បទ

(បទបថ្យាវត្ត)

**នមោ អរហតោ សម្មា សម្ពុទ្ធស្ស មហេសិនោ**
សូមថ្វាយបង្គំឆ្ពោះព្រះអរហន្ត សម្ពុទ្ធភគវន្តកាលស្វែងរកធម៌
គឺពោធិញាណប្រសើរបវរ បានត្រាស់ដឹងធម៌ដោយអរិយមគ្គ ។

**នមោ ឧត្តមធម្មស្ស ស្វាក្ខាតស្សេវ តេនិធ ។**
សូមថ្វាយបង្គំព្រះធម៌ឧត្តម ដែលព្រះបរមសម្ពុទ្ធសម្តែង
ដោយប្រពៃពិតប្រាកដជាក់ស្តែង ព្រះធម៌នោះឯងទុកក្នុងសាសនា ។
**នមោ មហាសង្ឃស្សាបិ វិសុទ្ធសីលទិដ្ឋិនោ**
សូមថ្វាយបង្គំព្រះសង្ឃប្រសើរ ដែលលោកបានធ្វើទិដ្ឋិនិងសីល
អោយបានបរិសុទ្ធផុតចាកមន្ទិល គឺទិដ្ឋិសីលលោកស្អាតអស់ហើយ ។

**នមោ ឱមាត្យារទ្ធស្ស រតនត្តយស្ស សាធុកំ ។**
សូមថ្វាយបង្គំប្រជុំត្រ័យរត្ន ប្រារព្ធដោយបទមានបីប្រការ
ព្រះពុទ្ធព្រះធម៌ព្រះសង្ឃឈ្នះមារ ប្រសើរអស្ចារ្យថ្លឹងថ្លែងពុំបាន ។

**នមោ ឱមកាតីតស្ស តស្ស វត្ថុត្តយស្សបិ**
សូមថ្វាយបង្គំភ្នុំវត្ថុបី ពិសេសពិសីប្រសើរថ្កើងថ្កាន
ព្រះពុទ្ធព្រះធម៌ព្រះសង្ឃសព្វឋាន ថយឬកល្យាណដោយគុណគួរគាប់។
**នមោ ការប្បភាវេន វិគច្ឆន្តុ ឧបទ្ទវា ។**
សូមថ្វាយបង្គំត្រ័យរត្នសោភា ឧបទ្រពនានាចូរវិនាសបាត់
ដោយអានុភាពបុណ្យជួយកម្ចាត់ ធ្វើក្តីវិបត្តិអោយស្ងប់សូន្យទៅ ។

៥៣

**នមោ ភាវានុភាវេន** **សុខត្ថិ ហោតុ សព្វទា**

សូមថ្វាយបង្គំត្រ័យរត្នទាំងបី សូមសុខសួស្តីកើតសព្វវេលា
ដោយអានុភាពធ្វើការវន្ទា គោរពបូជាឆ្ពោះព្រះត្រ័យរត្ន ។

**នមោ ភាវស្ស តេជេន** **ទិដ្ឋិម្ហិ ហោតិ តេជវា ។**

សូមថ្វាយបង្គំត្រ័យរត្នសោភា តេជះចេស្តាចូរមានដល់ខ្ញុំ
ក្នុងពិធីធ្វើកិច្ចថ្វាយបង្គំ តេជះបុណ្យធំសូមកើតមានឡើង ។

## បេមតោ

**បេមតោ ជាយតេ សោកោ បេមតោ ជាយតេ ភយំ**
**បេមតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ**
សេចក្តីទុក្ខសោកមកពីស្រឡាញ់ សេចក្តីខឹងខ្ញាញ់មកពីស្នេហា
នឹងផុតទុក្ខសោករោគភ័យនេះណា ត្រូវលះស្នេហាចោលចេញអោយផុត ។

**រតិយា ជាយតេ សោកោ រតិយា ជាយតេ ភយំ**
**រតិយា វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ**
សេចក្តីទុក្ខសោកមកពីតម្រេក អស់ភ័យបាត់ត្រេកព្រោះគ្មានស្នេហា
នឹងផុតទុក្ខសោករោគភ័យនេះណា ត្រូវលះស្នេហាគ្រឿងត្រាំចោលចេញ ។

**កាមតោ ជាយតេ សោកោ កាមតោ ជាយតេ ភយំ**
**កាមតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ**
សេចក្តីទុក្ខសោកមកពីតួកាម ភ័យស្អប់ជាប់តាមមកពីស្នេហា
នឹងផុតទុក្ខសោករោគភ័យនេះណា ត្រូវលះកាមាសារៈចោលចេញ ។

**តណ្ហាយ ជាយតេ សោកោ តណ្ហាយ ជាយតេ ភយំ**
**តណ្ហាយ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ**
សេចក្តីទុក្ខសោកមកពីតណ្ហា ភ័យស្លុតឫស្យាមកពីចិត្តចង់
នឹងផុតទុក្ខសោករោគភ័យឃ្លាតបង់ ត្រូវលះចំណង់តណ្ហាចោលចេញ ។

# អដ្ឋមហាឋាន

ស្ថានធំទាំងឡាយ ប្រាំបីកន្លែង ជាទីស្ញប់ស្ញែង ដល់ពពួកសត្វ
ទី ១ ឱទ្យាន ជាឋានព្រៃស្ងាត់ គឺព្រៃរាំងរតន៍ ដែលទ្រង់ប្រសូត្រ ។
ទី ២ ប្រសើរ ដែលព្រះទ្រង់ស្រូត ត្រាស់ក្រោមដើមពោ-ធិព្រឹក្សឧត្តម
ទី ៣ កន្លែង ដែលព្រះបរម សម្ដែងព្រះធម្ម ឈ្មោះធម្មចក្រ ។
ប្រោសភិក្ខុ៥អង្គ គឺពួកបញ្ចវគ្គ ធ្លាប់ឧបដ្ឋាក បម្រើព្រះអង្គ
ដោយព្រះទ័យថ្លៃ មិនអាចលះបង់ ហើយយាងតម្រង់ ពីដើមជ្រៃទៅ ។
ទី ៤ ជាទី ដែលទ្រង់គង់នៅ ក្នុងឋានព្រៃជ្រៅ ឈ្មោះបាលិល័យ
ទីនោះគ្មានមនុស្ស មានតែសត្វព្រៃ សត្វដំរីថ្លៃ បម្រើព្រះអង្គ ។
ទី ៥ ឈ្មោះ រតនបល្ល័ង្ក គឺទីទ្រង់ច្បាំង នាឡាគិរី
ពេលនោះមានមនុស្ស បែកពួកជាពីរ ទៅមើលពិធី សម្ដេចសម្ពុទ្ធ ។
ទី ៦ កាល ព្រះសព្វញ្ញុត្ត- ញាណជាមុុដ ធ្វើបាដិហារ្យ
ផ្ចាញ់ពួកនិគ្រន្ថ ក្រៅព្រះសាសនា ឈ្មោះល្បីអស្ចារ្យ គ្មានអ្នកណាដល់ ។
ទី ៧ កាល ព្រះទសពល គង់លើមណ្ឌល ថ្មព្រះឥន្ទ្រា
ហើយទ្រង់សម្ដែង នូវព្រះធម្មា ប្រាកដនាមថា ព្រះអភិធម្ម
សងគុណមាតា ដែលជាគុណធំ លើព្រះបរម សម្ពុទ្ធោ ។
ទី ៨ កាលព្រះ អរហំទ្រង់ផ្ទុំ ក្រោមដើមរាំងភ្នំ សាលព្រឹក្សទាំងគូ
ពេលនោះឯងហើយ ព្រះសព្វញ្ញូ ព្រះអង្គជាគ្រូ យាងចូលនិព្វាន ។
ស្ថានធំប្រាំបី កន្លែងនេះមាន ប្រតិស្ឋាន ក្នុងជម្ពូទ្វីបា
ជាទីដែលមនុស្ស និងទេវតា ឱនអង្គនមស្សការ គោរពបូជា ។
ខ្ញុំម្ចាស់ឱនកាយ បង្គំវន្ទា ដល់ឋានធំធារ ប្រាំបីកន្លែង
សូមសុខចម្រើន កើតយូរអង្វែង ទុក្ខទោសចំបែង កុំកើតមានឡើយ ៕

## ពុទ្ធជយមង្គលគាថា

**ពាហុំ សហស្សមភិនិម្មិតសាទុធន្តំ, គ្រីមេខលំ ឧទិតឃោរសសេន មារំ ទានាទិធម្មវិធិនា ជិតវា មុនិន្ទោ, តន្តេជសា ភវតុ តេ ជយមង្គលានិ ។**

ព្រះមុនិន្ទលោកាចារ្យ ផ្ចាញ់ក្រុងមារចិត្តមោហន្ធ
និម្មិតដៃមួយពាន់ កាន់សស្ត្រាវុធនានា ។
ជិះគ្រីមេខលជាតិ កោញ្ជនាទខ្ទរពសុធា
ព្រមដោយមារសេនា ពន្លឹកលន់កងស័ព្ទសាន ។
ដោយធម្មពិធី ទានបារមីជាប្រធាន
ក្រុងមារចាញ់ទ្រង់ញាណ ប្រណម្យកាយថ្វាយវន្ទា ។
រីជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជះជយា ព្រះឈ្នះមារគ្រានោះហោង ។

**មារាតិរេកមភិយុជ្ឈិតសព្វរត្តឹ, ឃោរម្បនាឡវកមក្ខមថទ្ធយក្ខំ ខន្តីសុទន្តវិធិនា ជិតវា មុនិន្ទោ, តន្តេជសា ភវតុ តេ ជយមង្គលានិ**

ព្រះមុនិន្ទពិននាយក ផ្ចាញ់អាឡវកយក្សឃោរឃៅ
រឹងរូសមិនតាំងនៅ ក្នុងខន្តីគុណសត្យា ។
រហូតអស់រាត្រី ព្រះជិនស្រីទ្រង់យុទ្ធនា
ក្រែលែងក្រុងមារា ក្នុងបឋមសម្ពោធិ ។
ដោយព្រះពិធីញាណ ទ្រង់ទូន្មានដោយខន្តី
ញុំាងចិត្តអសុរី ឱ្យបង់ព្យុះចុះវន្ទា ។
រីជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជះជយា ព្រះឈ្នះអាឡវកយក្សហោង ។

**នាឡាគិរឹ គជវរំ អតិមត្តភូតំ, ធាវគ្គិចក្កមសនីវ សុទារុណន្តំ**
**មេត្តម្ពុសេកវិធិនា ជិតវា មុនិន្ទោ, តន្តេជសា ភវតុ តេ ជយមង្គលានិ ។**

ព្រះមុនិន្ទពិនជិនស្រី ផ្ចាញ់ដំរីឈ្មោះនាឡា
គិរីវរគជា ដ៏ហានក្លាចុះប្រេងព្រេច ។
សាហាវឆាវឆេះក្រៃ ដូចភ្លើងព្រៃឆេះកំទេច
មុតដូចចក្រក្រុតពេជ្រ ខ្លាំងដូចកាំអសនី ។
ដោយព្រះពិធីស្រេព ស្រោចទឹកអប់គឺបារមី
មេត្តាព្រះជិនស្រី ញ៉ាំងដំរីឱ្យជ្រះថ្លា ។
វិជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជះជយា ព្រះឈ្មោះនាឡាគិរី ។

**ឧក្ខិត្តខគ្គមតិហត្ថសុទារុណន្តំ, ធាវន្តិ យោជនបថង្គុលិមាលវន្តំ**
**ឥទ្ធីភិសង្ខតមនោ ជិតវា មុនិន្ទោ, តន្តេជសា ភវតុ តេ ជយមង្គលានិ ។**

ព្រះមុនិន្ទពិនលោកត្រ័យ មានព្រះទ័យធ្វើបាដិហារ្យ
ផ្ចាញ់ចោរអង្គុលិមាល មានកម្រងគឺម្រាមដៃ ។
នៃមនុស្សដែលគាត់កាត់ មកដោតចាត់ជាមាល័យ
អង់អាចកំណាចក្រៃ ដ៏មានដៃស្ទាត់ប្រហារ ។
កាន់ដាវងារគ្រវី ដេញព្រះមុនីសាស្តាចារ្យ
ចម្ងាយផ្លូវកន្តារ កណ្តាលព្រៃបីយោជនា ។
វិជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជះជយា ព្រះឈ្មោះអង្គុលិមាល៍ ។

**កត្វាន កដ្ឋមុទរំ ឥវ គព្ភិនីយា, ចិញ្ចាយ ទុដ្ឋវចនំ ជនកាយមជ្ឈេ**
**សន្តេន សោមវិធិនា ជិតវា មុនិន្ទោ, តន្តេជសា ភវតុ តេ ជយមង្គលានិ។**

ព្រះមុនិន្ទមានព្រះភាគ ផ្ចាញ់ទ្រុស្តពាក្យនាងចិញ្ចា
អំពើធ្វើដូចជា ស្រីមានគភ៌ចាស់ចើសពោះ ។

យកឈើធ្វើជាកូន ព័ទ្ធពោះខ្លួនពោលទ្រគោះ
ព្រះពុទ្ធឈ្នះកាលនោះ ដោយសមាចារពិធី ។
រម្ងាប់ពាក្យចណ្ឌាល នាកណ្ដាលជនប្រុសស្រី
ចិញ្ចាចាញ់បារមី គឺសច្ចំពាក្យសត្យា ។
រីជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជះជយា ព្រះសាស្ដាឈ្នះចិញ្ចា ។

**សច្ចំ វិហាយមតិសច្ចកវាទកេតុំ, វាទាភិរោបិតមនំ អតិអន្ធភូតំ**
**បញ្ញាបទីបជលិតោ ជិតវា មុនិន្ទោ, តន្តេជសា ភវតុ តេ ជយមង្គលានិ ។**

ព្រះមុនិន្ទពិនអ្នកប្រាជ្ញ រុងរឿងស្វាចដោយបញ្ញា
ផ្ចាញ់សច្ចកៈជា និគ្រន្ថក្រៅពុទ្ធវិន័យ ។
អធ្យាស្រ័យលះបង់ ពាក្យសត្យត្រង់តាមគាប់ចៃ
សរសើរខ្លួនឯងក្រៃ លើកកំពស់ដូចដងទង់ ។
បង្កើតមោហ៍ងងឹត ដោយពោលឥតពាក្យទៀងត្រង់
ព្រះទ្រង់កម្ចាត់បង់ ដោយប្រទីបគឺបញ្ញា ។
រីជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជះជយា ឈ្នះសច្ចកៈនិគ្រន្ថ ។

**នន្ទោបនន្ទភុជគំ វិពុធំ មហិទ្ធឹ, បុត្តេន ថេរភុជគេន ទមាបយន្តោ**
**ឥទ្ធូបទេសវិធិនា ជិតវា មុនិន្ទោ, តន្តេជសា ភវតុ តេ ជយមង្គលានិ ។**

ព្រះមុនិន្ទពិនទ្រង់ញាណ ញ៉ាំងមោគ្គល្លានមានអំណាច
ឱ្យប្លែងជានាគរាជ ទៅទូន្មានព្យសនីភុជង្គ ។
ឈ្មោះនន្ទោបនន្ទ ចិត្តមោហន្ធរឿងឫទ្ធិរង្គ
ទិដ្ឋិកាចទ្រនង់ ទ្រង់ផ្ចាញ់ដោយពិធីឈាន ។
គឺឱ្យឧបទេស ឫទ្ធិវិសេសដល់មោគ្គល្លាន
ឫទ្ធិនាគអន្តរធាន ឱនចុះចាញ់ព្រះចេស្ដា ។

វិជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជះជយា ព្រះភគវាឈ្នះនាគហោង ។

**ទុគ្គាហទិដ្ឋិភុជគេន សុទដ្ឋហត្ថំ, ព្រហ្មំ វិសុទ្ធិជុតិមិទ្ធិពកាភិធានំ**
**ញាណាគទេន វិធិនា ជិតវា មុនិន្ទោ, តន្តេជសា ភវតុ តេ ជយមង្គលានិ**

ព្រះមុនិន្ទពិនគោតម ផ្ចាញ់មហាព្រហ្មឈ្មោះពកា
សំគាល់ថាអាត្មា រុងរឿងដោយគុណបរិសុទ្ធ ។
ដៃកាន់អាសិរ្ពិស គឺចិត្តទ្រឹស្ដិដ៏មោះមុត
កាន់ខុសផ្លូវសម្ពុទ្ធ មិនលើកលាកលះបង់ប្រាណ ។
ទ្រង់ឈ្នះដោយពិធី ឱសថវិសេសសម្រាន្ត
ផ្សំត្រូវគាប់សន្ដាន គឺព្រះញាណប្រោសទេសនា ។
វិជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជះជយា ឈ្នះព្រហ្មាឥតមានហ្មង ។

**ឯតាបិ ពុទ្ធជយមង្គលអដ្ឋគាថា, យោ វាចនោ ទិនទិនេ សរតេ មតន្ទី**
**ហិត្វាននេកវិវិធានិ ចុបទ្ទវានិ, មោក្ខំ សុខំ អធិគមេយ្យ នរោ សបញ្ញោ។**

យោ នរោ ជនឯណា កបបញ្ញាប្រាសក្ដីខ្ជិល
ឧស្សាហ៍សាងទានសីល សូត្ររំលឹកព្រះធម៌ថ្លៃ ។
គាថាប្រាំបីបទ នេះកំណត់ឈ្មោះពុទ្ធជ័យ
ខំសូត្រសព្វៗថ្ងៃ កើតមង្គលជានិរន្តរ៍ ។
សោ នរោ វិជននោះ បានរំដោះរោគអាសន្ន
ឧបទ្រពអនេកលន់ មានប្រការផ្សេងៗផង ។
នឹងដល់ធម៌ក្សេមក្សាន្ត គឺនិព្វានសុខកន្លង
លែងទុក្ខទាំងបួនកង ដោយពុទ្ធជ័យមង្គលនេះ ។

## មង្គលសូត្រប្រែ

**"ពហូ ទេវា មនុស្សា ច, មង្គលានិ អចិន្តយុំ,**
**អាកង្ខមានា សោត្ថានំ, ព្រូហិ មង្គលមុត្តមំ" ។**

ទេវតាមនុស្សទាំងឡាយ គិតខ្វល់ខ្វាយរកមង្គល
សូមទានព្រះទសពល ប្រាប់មង្គលដ៏ឧត្តម ។

**អសេវនា ច ពាលានំ, បណ្ឌិតានញ្ច សេវនា,**
**បូជា ច បូជនីយានំ, ឯតម្មង្គលមុត្តមំ ។**

ព្រះពុទ្ធទ្រង់ត្រាស់ថា កុំសេ្នហាពួកពាលធំ
គួរស្និទ្ធបណ្ឌិតសម ហើយឱ្យធ្វើការបូជា ។
ដល់លោកអ្នកដែលគួរ ទើបនាំតួទៅសួគ៌ា
ទាំងបីនេះហៅថា ជាមង្គលដ៏ឧត្តម ។

**បតិរូបទេសវាសោ ច, បុព្វេ ច កតបុញ្ញតា,**
**អត្តសម្មាបណិធិ ច, ឯតម្មង្គលមុត្តមំ ។**

ការនៅក្នុងប្រទេស ល្អវិសេសប្លូកគួរសម
នឹងមានបុណ្យបានខំ សាងសន្សំទុកពីមុន
ហើយតាំងខ្លួនត្រូវល្អ តាមផ្លូវធម៌ប្រសើរលន់
ទាំងបីនេះជាបុណ្យ ជាមង្គលដ៏ឧត្តម ។

៦១

| | |
|---|---|
| **ពាហុសច្ចញ្ញា សិប្បញ្ញា,** | **វិនយោ ច សុសិក្ខិតោ,** |
| **សុភាសិតា ច យា វាចា,** | **ឯតម្មង្គលមុត្តមំ ។** |
| ការបានស្ដាប់ធម៌ច្រើន | និងក្រវើនរៀនសីលថ្លៃ |
| និងបានរៀនវិន័យ | ឆ្លាតវាងវៃជំនាញល្អ |
| សម្ដែងសុចរិត | សុភាសិតតាមផ្លូវធម៌ |
| ទាំងបួនយ៉ាងនេះក៏ | ជាមង្គលដ៏ឧត្ដម ។ |
| **មាតាបិតុឧបដ្ឋានំ,** | **បុត្តទារស្ស សង្គហោ,** |
| **អនាកុលា ច កម្មន្តា,** | **ឯតម្មង្គលមុត្តមំ ។** |
| បម្រើអ្នកមាតា | និងបិតាមានគុណធំ |
| សង្គ្រោះបុត្រភិរម្យ | និងឧបត្ថម្ភដល់ភរិយា |
| ធ្វើកិច្ចការអ្វីៗ | ខំឃ្មាតខ្មីមិនចោលការ |
| ទាំងបួននេះហៅថា | ជាមង្គលដ៏ឧត្ដម ។ |
| **ទានញ្ច ធម្មចរិយា ច,** | **ញាតកានញ្ច សង្គហោ,** |
| **អនវជ្ជានិ កម្មានិ,** | **ឯតម្មង្គលមុត្តមំ ។** |
| ការឱ្យវត្ថុទាន | ធម៌ក៏បានប្រព្រឹត្តមាំ |
| សង្គ្រោះញាតិតូចធំ | តាមគួរសមទោះជិតឆ្ងាយ |
| កិច្ចការណាឥតទោស | ឬមិនខុសក៏ខ្វល់ខ្វាយ |
| ទាំងបួនដែលអធិប្បាយ | ជាមង្គលដ៏ឧត្ដម ។ |

**អារតី វិរតី បាបា,** **មជ្ជបានា ច សញ្ញមោ,**
**អប្បមាទោ ច ធម្មេសុ,** **ឯតម្មង្គលមុត្តមំ ។**

ការលះវាចាបាប សង្រួមភាពកាយរឿយៗ
ប្រយ័ត្នមិនធ្វេសឡើយ មិនហ៊ានផឹកទឹកស្រវឹង
ធម៌អាថ៌ផងទាំងឡាយ មិនមើលងាយប្រមាទខឹង
ទាំងបីយ៉ាងនេះសឹង ជាមង្គលដ៏ឧត្តម ។

**គារវោ ច និវាតោ ច,** **សន្តុដ្ឋី ច កតញ្ញុតា,**
**កាលេន ធម្មស្សវនំ,** **ឯតម្មង្គលមុត្តមំ ។**

សេចក្តីគារវៈ ដល់លោកអ្នកដែលគួរផង
បន្ទាបខ្លួនឥតឆ្គង ព្រមទាំងមានក្តីសន្តោស
និងមានកតញ្ញូ ចេះស្តាប់ធម៌របស់សប្បុរស
ទាំងប្រាំនេះចំពោះ ជាមង្គលដ៏ឧត្តម ។

**ខន្តី ច សោវចស្សតា,** **សមណានញ្ច ទស្សនំ,**
**កាលេន ធម្មសាកច្ឆា,** **ឯតម្មង្គលមុត្តមំ ។**

សេចក្តីអត់សង្កត់ ធន់អំណត់មិនញាប់ញ័រ
ជាអ្នកមានចិត្តល្អ គេប្រដៅបានដោយងាយ
កាលឃើញពួកសមណៈ គួរសួរធម៌យ៉ាងរីករាយ
ទាំងបួនដែលអធិប្បាយ ជាមង្គលដ៏ឧត្តម ។

**គារវោ ច និវាតោ ច,** | **សន្តុដ្ឋី ច កតញ្ញុតា,**

| | |
|---|---|
| **គរវោ ច ព្រហ្មចរិយញ្ច,** | **អរិយសច្ចាន ទស្សនំ,** |
| **និព្វានសច្ឆិកិរិយា ច,** | **ឯតម្មង្គលមុត្តមំ ។** |
| ព្យាយាមដុតកិលេស | ធម៌វិសេសប្រសើរក្រៃ |
| ប្រព្រឹត្តល្អប្រពៃ | ឃើញអរិយសច្ច ៤ |
| និងធ្វើព្រះនិព្វាន | ឱ្យច្បាស់បានយ៉ាងមាំមួន |
| អ្នកធ្វើកិច្ចទាំង ៤ | ជាមង្គលដ៏ឧត្តម ។ |
| **ផុដ្ឋស្ស លោកធម្មេហិ,** | **ចិត្តំ យស្ស ន កម្បតិ,** |
| **អសោកំ វិរជំ ខេមំ,** | **ឯតម្មង្គលមុត្តមំ ។** |
| ចិត្តនៃបុគ្គលណា | ដែលពោលថាដ៏ប្រសើរ |
| មិនជ្រួលមិនញាប់ញ័រ | តាមលោកធម៌ទាំងប្រាំបី |
| ជាចិត្តមានអធ្យោក | មិនសោយសោកប្រាសធូលី |
| ជាចិត្តក្សេមពេញទី | ទាំង ៤ នេះជាមង្គល ។ |
| **ឯតាទិសានិ កត្វាន,** | **សព្វត្ថមបរាជិតា,** |
| **សព្វត្ថ សោត្ថឹ គច្ឆន្តិ,** | **តន្តេសំ មង្គលមុត្តមន្តិ ។** |
| ពួកមនុស្សឬទេវតា | ពួកឯណាមានកុសល |
| បានធ្វើនូវមង្គល | ៣៨ នេះឯង |
| ពួកនោះមិនថយថោក | ខ្ពស់ក្នុងលោកឥតថ្លឹងថ្លែង |
| ហើយបានសុខជាក់ស្តែង | ប្រាកដក្នុងទីទាំងពួង ។ |
| ការនោះជាមង្គល | ឧត្តមដល់មនុស្សលោកហោង |
| ព្រមទាំងទេវតាផង | ដោយទំនងយ៉ាងនេះឯង |
| មង្គលអម្បាលនោះ | ព្រះសម្ពុទ្ធទ្រង់សម្តែង |
| អត្ថកថាចែង | មនុស្សត្រូវស្វែងរករៀនចុះ ។ |

## បរាភវសូត្រ

(បទបរ្យាវត្ត)

**"នេវតាទាំងឡាយចូលក្រាបបង្គំ ទូលសួរព្រះបរមសាស្តាថា៖"**

**បរាភវន្តំ បុរិសំ មយំ បុច្ឆាម គោតមំ**

**ភវន្តំ បុដ្ឋុមាគម្ម កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយមកសូមទូលសួរ នូវហេតុដែលគួរចម្រើនវិនាស

ប្រុសស្រីក្នុងលោកសន្និវាស ដែលនឹងវិនាសសាបសូន្យចាកគុណ ។

ឆ្ពោះព្រះគោតមព្រះអង្គមានបុណ្យ មេត្តានិមន្តសម្ដែងឱ្យទាន

ធម្មជាតដូចម្ដេចដែលជាប្រធាន នាំសត្វឱ្យមានសេចក្ដីវិនាស ។

**សុវិជានោ ភវំ ហោតិ ទុវិជានោ បរាភវោ**

**ធម្មកាមោ ភវំ ហោតិ ធម្មទេស្សី បរាភវោ ។**

អ្នកដែលចម្រើនតថាគតស្គាល់ងាយ អ្នកដែលអន្តរាយតថាគតស្គាល់ពិត

អ្នកប្រាថ្នាធម៌ល្អិតល្អក្នុងចិត្ត ហើយខំប្រព្រឹត្តនឹងបានចម្រើន ។

អ្នកដែលទ្រុស្តធម៌ស្អប់ធម៌ឥតកើន ឥតកើតចម្រើនវិនាសទៅមុខ ។

**ឥតិ ហេតំ វិជានាម បឋមោ សោ បរាភវោ**

**ទុតិយំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្ដែង វិនាសនេះឯងព្រោះហេតុដូច្នោះ

ក្ដីវិនាសនេះបើរាប់សង្គ្រោះ វិនាសនោះឈ្មោះទី១ទាន់ហាន់ ។

បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសម្ដែងឱ្យទាន

វិនាសទី២អ្វីជាប្រធាន នាំសត្វឱ្យមានសេចក្ដីវិនាស ។

**អសន្តស្ស បិយា ហោន្តិ សន្តេ ន កុរុតេ បិយំ**

**អសតំ ធម្មំ រោចេតិ តំ បរាភវតោ មុខំ ។**

៦៥

អ្នកដែលស្រឡាញ់ពេញចិត្តស្នេហា
តែងមិនស្រឡាញ់ពេញចិត្តទាំងអស់
សេចក្ដីស្រឡាញ់ពេញចិត្តគំនិត
គាប់ចិត្តក្នុងធមិឬមួយរបស់

តែនឹងមនុស្សណាអសប្បុរស
នឹងអ្នកសប្បុរសមកធ្វើជាមិត្រ ។
ហើយទៅគប់មិត្រអសប្បុរស
ហេតុនោះទាំងអស់នាំឱ្យវិនាស ។

**ឥតិ ហេតំ វិជានាម ទុតិយោ សោ បរាភវោ**
**តតិយំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្ដែង
ក្ដីវិនាសនេះបើរាប់សង្គ្រោះ
បពិត្រព្រះអង្គព្រះនាមភគវន្ត
វិនាសទី៣អ្វីជាប្រធាន

វិនាសនេះឯងព្រោះហេតុដូច្នោះ
វិនាសនោះឈ្មោះទី២ទាន់ហាន់ ។
សូមទ្រង់និមន្តសម្ដែងឱ្យទាន
នាំសត្វឱ្យមានសេចក្ដីវិនាស ។

**និទ្ទាសីលី សភាសីលី អនុដ្ឋាតា ច យោ នរោ**
**អលសោ កោធបញ្ញាណោ តំ បរាភវតោ មុខំ ។**

អ្នកដេកច្រើន១ និយាយច្រើន១
អ្នកខ្ជិលប្រអូសមិនមានខ្នះខ្នែង
ហេតុធមិទាំងនោះមិនជាកល្យាណ
មានជាប្រធានតិចច្រើនដោយហោច

និងអ្នកឥតព្យួយឥតគិតប្រឹងប្រែង
ខឹងច្រើនសម្ដែងឱ្យគេឃើញបាន ។
នាំឱ្យខកខានខាតខូចប្រយោជន៍
នាំបង់ប្រយោជន៍ហើយឱ្យវិនាស ។

**ឥតិ ហេតំ វិជានាម តតិយោ សោ បរាភវោ**
**ចតុត្ថំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្ដែង
ក្ដីវិនាសនេះបើរាប់សង្គ្រោះ
បពិត្រព្រះអង្គព្រះនាមភគវន្ត
វិនាសទី៤អ្វីជាប្រធាន

វិនាសនេះឯងព្រោះហេតុដូច្នោះ
វិនាសនោះឈ្មោះទី៣ទាន់ហាន់ ។
សូមទ្រង់និមន្តសម្ដែងឱ្យទាន
នាំសត្វឱ្យមានសេចក្ដីវិនាស ។

**យោ មាតរំ បិតរំ វា    ជិណ្ណកំ គតយោព្វនំ**
**បហុសន្តោ ន ភរតិ    តំ បរាភវតោ មុខំ ។**
នរជនណាមានទ្រព្យធនធាន    ហើយខ្លួនមិនបានចិញ្ចឹមរក្សា
មាតាបិតាដែលចាស់ជរា    ហេតុនោះទៅជានាំឱ្យវិនាស ។
**ឥតិ ហេតំ វិជានាម    ចតុត្ថោ សោ បរាភវោ**
**បញ្ចមំ ភគវា ព្រូហិ    កឹ បរាភវតោ មុខំ ។**
យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង    វិនាសនេះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ    វិនាសនោះឈ្មោះទី៤ទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត    សូមទ្រង់និមន្តសម្តែងឱ្យទាន
វិនាសទី៥អ្វីជាប្រធាន    នាំសត្វឱ្យមានសេចក្តីវិនាស ។
**យោ សមណំ ព្រាហ្មណំ វា    អញ្ញំ វាបិ វនិព្វកំ**
**មុសាវាទេន វញ្ចេតិ    តំ បរាភវតោ មុខំ ។**
ជនបញ្ឆោតព្រាហ្មណ៍ឬពួកសមណៈ    ពួកស្មូមឬអ្នកដទៃៗ
ដោយមុសាវាទឃ្លាតពាក្យប្រពៃ    នោះប្រធាននៃសេចក្តីវិនាស ។
**ឥតិ ហេតំ វិជានាម    បញ្ចមោ សោ បរាភវោ**
**ឆដ្ឋមំ ភគវា ព្រូហិ    កឹ បរាភវតោ មុខំ ។**
យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង    វិនាសនេះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ    វិនាសនោះឈ្មោះទី៥ទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត    សូមទ្រង់និមន្តសម្តែងឱ្យទាន
វិនាសទី៦អ្វីជាប្រធាន    នាំសត្វឱ្យមានសេចក្តីវិនាស ។
**បហុតវិត្តោ បុរិសោ    សហិរញ្ញោ សភោជនោ**
**ឯកោ ភុញ្ជតិ សាទូនិ    តំ បរាភវតោ មុខំ ។**

បុរសអ្នកមានទ្រព្យធនធានច្រើន    មាសប្រាក់ចម្រើននិងគ្រឿងអាហារ
លបលាក់របស់ដែលឆ្ងាញ់ពិសា    ស៊ីម្នាក់ឯងជាប្រធានវិនាស ។
**ឥតិ ហេតំ វិជានាម    ឆដ្ឋមោ សោ បរាភវោ**
**សត្តមំ ភគវា ព្រូហិ    កឹ បរាភវតោ មុខំ ។**
យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង    វិនាសនេះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ    វិនាសនោះឈ្មោះទី៦ទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត    សូមទ្រង់និមន្តសម្តែងឱ្យទាន
វិនាសទី៧អ្វីជាប្រធាន    នាំសត្វឱ្យមានសេចក្តីវិនាស ។
**ជាតិត្ថទ្ធោ ធនត្ថទ្ធោ    គោត្តត្ថទ្ធោ ច យោ នរោ**
**សញ្ញាតឹ អតិមញ្ញេតិ    តំ បរាភវតោ មុខំ ។**
អ្នកដែលប្រកាន់ជាតិទ្រព្យត្រកូល    ហើយមិនប្រមូលសាច់ញាតិសន្តាន
មើលងាយញាតិខ្លួនដោយអាងខ្លួនមាន    នោះជាប្រធានសេចក្តីវិនាស ។
**ឥតិ ហេតំ វិជានាម    សត្តមោ សោ បរាភវោ**
**អដ្ឋមំ ភគវា ព្រូហិ    កឹ បរាភវតោ មុខំ ។**
យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង    វិនាសនេះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ    វិនាសនោះឈ្មោះទី៧ទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត    សូមទ្រង់និមន្តសម្តែងឱ្យទាន
វិនាសទី៨អ្វីជាប្រធាន    នាំសត្វឱ្យមានសេចក្តីវិនាស ។
**ឥត្ថីធុត្តោ សុរាធុត្តោ    អក្ខធុត្តោ ច យោ នរោ**
**លទ្ធំ លទ្ធំ វិនាសេតិ    តំ បរាភវតោ មុខំ ។**
ជនអ្នកប្រព្រឹត្តល្បែងបីប្រការ    ល្បែងស្រីល្បែងស្រាល្បែងភ្នាល់ទាំងឡាយ
ធ្វើទ្រព្យខ្លួនមានឱ្យអន្តរាយ    ការល្បែងទាំងឡាយនោះនាំវិនាស ។

**ឥតិ ហេតំ វិជានាម** **អដ្ឋមោ សោ បរាភវោ**
**នវមំ ភគវា ព្រូហិ** **កឹ បរាភវតោ មុខំ ។**
យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនេះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ វិនាសនោះឈ្មោះទី៨ទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសម្តែងឱ្យទាន
វិនាសទី៩អ្វីជាប្រធាន នាំសត្វឱ្យមានសេចក្តីវិនាស ។
**សេហិ ទារេហិ អសន្តុដ្ឋោ** **វេសិយាសុ បទុស្សតិ**
**ទុស្សតិ បរទារេសុ** **តំ បរាភវតោ មុខំ ។**
ប្រុសមិនត្រេកអរនឹងប្រពន្ធខ្លួន ហើយទៅជាប់ជួននឹងស្រីពេស្យា
ទ្រុស្តនឹងប្រពន្ធកូនជននានា ហេតុនោះទៅជានាំឱ្យវិនាស ។
**ឥតិ ហេតំ វិជានាម** **នវមោ សោ បរាភវោ**
**ទសមំ ភគវា ព្រូហិ** **កឹ បរាភវតោ មុខំ ។**
យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនេះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ វិនាសនោះឈ្មោះទី៩ទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសម្តែងឱ្យទាន
វិនាសទី១០អ្វីជាប្រធាន នាំសត្វឱ្យមានសេចក្តីវិនាស ។
**អតីតយោព្វនោ បោសោ** **អានេតិ តិម្ពរុត្ថនឹ**
**តស្សា ឥស្សា ន សុបតិ** **តំ បរាភវតោ មុខំ ។**
បុរសមានវ័យដែលចាស់ហួសពេក ហើយមានតម្រេក ដោយក្តីតណ្ហា
នាំយកស្រីក្មេងមកធ្វើភរិយា ហេតុនោះទៅជានាំឱ្យវិនាស ។
**ឥតិ ហេតំ វិជានាម** **ទសមោ សោ បរាភវោ**
**ឯកាទសមំ ភគវា ព្រូហិ** **កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនេះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ វិនាសនោះឈ្មោះទី១០ទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសម្តែងឱ្យទាន
វិនាសទី១១អ្វីជាប្រធាន នាំសត្វឱ្យមានសេចក្តីវិនាស ។

**ឥត្ថី សោណ្ឌី វិកិរណី បុរិសំ វាបិ តាទិសំ**
**ឥស្សរិយស្មឹ ឋបេតិ តំ បរាភវតោ មុខំ ។**

បុរសតាំងស្រីអ្នកលេងខ្ជះខ្ជាយ ឬស្រីទាំងឡាយតាំងបុរសនោះ
ដែលជាអ្នកលេងខ្ជះខ្ជាយដូច្នោះ អំពើទាំងនោះនាំឱ្យវិនាស ។

**ឥតិ ហេតំ វិជានាម ឯកាទសមោ សោ បរាភវោ**
**ទ្វាទសមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនេះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ វិនាសនោះឈ្មោះទី១១ទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសម្តែងឱ្យទាន
វិនាសទី១២អ្វីជាប្រធាន នាំសត្វឱ្យមានសេចក្តីវិនាស ។

**អប្បភោគោ មហាតណ្ហោ ខត្តិយេ ជាយតេ កុលេ**
**សោ ច រជ្ជំ បត្ថយតិ តំ បរាភវតោ មុខំ ។**

ជនណាកើតក្នុងត្រកូលជាក្សត្រ អ្នកក្សត់សម្បត្តិហើយប្រាថ្នាធំ
ចង់បានជាស្តេចសោយរាជ្យស្តុកស្តម្ភ ហេតុនោះនឹងនាំឱ្យដល់វិនាស ។

**ឯតេ បរាភវេ លោកេ បណ្ឌិតោ សមវេក្ខិយ**
**អរិយទស្សនសម្បន្នោ ស លោកំ ភជតេ សិវំ ។**

ជនជាបណ្ឌិតគំនិតប្រសើរ បានឃើញដំណើរនៃហេតុវិនាស
ដល់សត្វក្នុងលោកសន្និវាស គេចពីវិនាសគប់រកចម្រើន ។

(បរាភវសុត្តំ និដ្ឋិតំ)

## អភយបរិត្តគាថា

យន្ទុន្និមិត្តំ អវមង្គលញ្ច យោ ចាមនាបោ សកុណស្ស សទ្ទោ
បាបគ្គហោ ទុស្សុបិនំ អកន្តំ ពុទ្ធានុភាវេន វិនាសមេន្តុ

និមិត្តអាក្រក់ឯណាក្តី អពមង្គលឯណាក្តី សំឡេងសត្វមិនជាទីគាប់ចិត្តឯណាក្តី
បាបគ្រោះឯណាក្តី សុបិនអាក្រក់ មិនជាទីពេញចិត្តឯណាក្តី
ដោយអានុភាពនៃព្រះពុទ្ធជាម្ចាស់ សូមឱ្យនិមិត្តអាក្រក់ជាដើមនោះ
ដល់នូវសេចក្តីវិនាសបាត់បង់ទៅ ។

យន្ទុន្និមិត្តំ អវមង្គលញ្ច យោ ចាមនាបោ សកុណស្ស សទ្ទោ
បាបគ្គហោ ទុស្សុបិនំ អកន្តំ ធម្មានុភាវេន វិនាសមេន្តុ

និមិត្តអាក្រក់ឯណាក្តី អពមង្គលឯណាក្តី សំឡេងសត្វមិនជាទីគាប់ចិត្តឯណាក្តី
បាបគ្រោះឯណាក្តី សុបិនអាក្រក់ មិនជាទីពេញចិត្តឯណាក្តី
ដោយអានុភាពនៃព្រះធម៌ សូមឱ្យនិមិត្តអាក្រក់ជាដើមនោះ
ដល់នូវសេចក្តីវិនាសបាត់បង់ទៅ ។

យន្ទុន្និមិត្តំ អវមង្គលញ្ច យោ ចាមនាបោ សកុណស្ស សទ្ទោ
បាបគ្គហោ ទុស្សុបិនំ អកន្តំ សង្ឃានុភាវេន វិនាសមេន្តុ

និមិត្តអាក្រក់ឯណាក្តី អពមង្គលឯណាក្តី សំឡេងសត្វមិនជាទីគាប់ចិត្តឯណាក្តី
បាបគ្រោះឯណាក្តី សុបិនអាក្រក់ មិនជាទីពេញចិត្តឯណាក្តី
ដោយអានុភាពនៃព្រះសង្ឃ សូមឱ្យនិមិត្តអាក្រក់ជាដើមនោះ
ដល់នូវសេចក្តីវិនាសបាត់បង់ទៅ ។

# ពុទ្ធសាសនពិធី

## បាលីវេរគ្រឿងសក្ការៈក្នុងថ្ងៃមាឃបូជា

អជ្ជាយំ ភោន្តោ មាឃបុណ្ណមី សម្បត្តា មាឃនក្ខត្តេន យុត្តោ បុណ្ណចន្ទោ ហោតិ តថា ហិ អរហន្តសម្មាសម្ពុទ្ធោ វេឡុវនេ កលន្ទកនិវាបេ មាឃបុណ្ណមិយំ វឌ្ឍមានកច្ឆាយាយ ចតុរង្គិកេ សាវកសន្និបាតេ ឱវាទបាតិមោក្ខំ ឧទ្ទិសិត្វា វិសុទ្ធុបោសថំ អកាសិ សព្វេសំ ខីណាសវានំយេវ អឌ្ឍតេឡសានំ ភិក្ខុសតានំ ។

អថ ច បន អម្ហាកំ លោកនាយកោ ចាបាលចេតិយេ សតោ សម្បជានោ អសីតិយា វស្សកាលេ ឥតោ តិណ្ណំ មាសានំ អច្ចយេន តថាគតោ បរិនិព្វាយិស្សាមីតិ អាយុសង្ខារំ ឱស្សជ្ជិ ឱស្សជ្ជិត្វា ច បន ភូមិចាលោ អហោសិ ។

តេនហិ មយន្ទានិ ឥមំ មាឃបុណ្ណមី នក្ខត្តសមយំ យថាតក្កាលសទិសំ សម្បត្តា តស្ស តំ តំ អនុស្សរមានា ឥធ សមាគតា រតនត្តយស្ស ឥមេហិ ទីបធូបបុប្ផាទិសក្ការេហិ អភិបូជេមិ សាធុ នោ ភន្តេ ភគវា សសាវកសង្ឃោ សុចិរបរិនិព្វុតោបិ ឥមេ សក្ការេ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

# ប្រែថា

បពិត្រលោកម្ចាស់ទាំងឡាយដ៏ចម្រើន ថ្ងៃនេះជាថ្ងៃមាឃពេញបូណ៌មី មកដល់ព្រមហើយ ប្រកបហើយ ដោយមាឃនក្ខត្តឫក្ស មានព្រះច័ន្ទពេញវង់ ប្រាកដសេចក្តីពិតថា កាលនោះព្រះអរហន្តសម្មាសម្ពុទ្ធ ទ្រង់ប្រថាប់នៅក្នុងវេឡុវ័នកលន្ទកនិវាបស្ថាន សម្តែងនូវឱវាទបាតិមោក្ខ ធ្វើវិសុទ្ធិឧបោសថ ចំពោះភិក្ខុ ដប់ពីររយ ដោយកន្លះគឺ (១២៥០) អង្គ សុទ្ធតែជាព្រះខីណាស្រពទាំងអស់ ក្នុងទីប្រជុំសាវ័ក ប្រកបដោយអង្គ៤ វេលារសៀល ថ្ងៃពេញបូណ៌មីខែមាឃ ។

មួយវិញទៀត សម្តេចព្រះលោកនាថជាម្ចាស់នៃយើង ទ្រង់ប្រថាប់នៅក្នុងបាវាលចេតិយ ទ្រង់មានសតិសម្បជញ្ញៈ ដាក់ចុះនូវជន្មាយុសង្ខារថា: កន្លងទៅបីខែទៀត រាប់តាំងអំពីខែនេះទៅ តថាគតនឹងបរិនិព្វាន ក្នុងគម្រប់ព្រះជន្មាយុ ៨០ ឆ្នាំគត់ លុះទ្រង់ដាក់ព្រះជន្មាយុសង្ខារហើយ ក៏កើតញាប់ញ័រផែនដី ។

ព្រោះហេតុនោះ ឥឡូវនេះ យើងខ្ញុំទាំងឡាយ (បើ) ដល់ថ្ងៃមាឃបុណ្ណមី ជានក្ខត្តសម័យ ប្រហែលដូចជា នក្ខត្តសម័យកាលនោះ ក៏រំឭកដល់នូវ កាលទាំងពីរនោះរបស់ព្រះដ៏មានព្រះភាគ ទើបមកជួបជុំគ្នា ក្នុងទីនេះ ធ្វើបូជាចំពោះព្រះរតនត្រ័យ ដោយគ្រឿងសក្ការៈបូជាទាំងឡាយ មានទៀនធូប កម្រងផ្កាជាដើមនេះ ។

បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ព្រមទាំងព្រះសង្ឃសាវ័ក សូម្បីបរិនិព្វាន ហើយជាយូរអង្វែង សូមទទួលនូវគ្រឿងសក្ការៈទាំងឡាយនេះ ដើម្បីជាប្រយោជន៍និងសេចក្តីសុខ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ៕

# គាថាប្រារព្ធមាឃបូជា

មាឃនក្ខត្តយុត្តាយ    បុណ្ណាយ បុណ្ណមាយំ យោ
អរហំ សម្មាសម្ពុទ្ធោ    ភគវា គោតមវ្ហយោ ។
សុទ្ធានន្តនយោ ញាណោ    សត្ថា លោកេ អនុត្តរោ
វិហរន្តោ រាជគហេ    មគធានំ គិរិព្វជេ ។
វិហារេ វេឡុវនេ    កលន្ទកនិវាបិយេ
សង្ឃស្ស សន្និបាតម្ហិ    ឧត្តមេ ចតុរង្គិកេ ។
អឌ្ឍតេលសេហិ ភិក្ខុ-    សតេហិ បរិវារិតោ
តីហិ គាថាហិ សំខិត្តំ    សព្វំ ពុទ្ធានសាសនំ ។
សមោសារេហិ ឱវាទំ    បាដិមោក្ខំ អនុត្តរំ
តមេវម្ហកសម្ពុទ្ធំ    សខីណាសវសាវកំ ។
ចិរកាលមតីតម្បិ    បសាទេន អនុស្សរំ
អយម្បិ បរិសា សព្វា    បសន្នា ធម្មគាមិនី ។
សម្បត្តា តាទិសំ កាលំ    សុនក្ខត្តំ សុមង្គលំ
ទីបធូបាទិសក្ការេ    អភិសង្ខ យថាពលំ ។
តេហិ បូជេតវេហដ្ឋ    កុដ្ឋា ឥធ សមាគតា
អភិវន្ទតិ បូជេតិ    ភគវន្តំ សសាវកំ ។
ភាលេន សម្មុខីភូតំ    អតីតារម្មណត្តនា
ឱសារន្តំ បាដិមោក្ខំ    វិសុទ្ធុត្តមុបោសថេ ។
ឥតោ ជេន សុបុញ្ញេន    សោត្ថិ ហោតុ សទាបិ នោ
សាសនំ សត្ថុ អម្ហាកំ    ចិរំ ទិប្បតុ តាទិនោតិ ។

# បទប្រឃ្លោង ៧ ពាក្យ

ព្រះមានព្រះភាគអង្គឯណា ទ្រង់ព្រះនាមថាព្រះគោតម
កម្ចាត់កិលេសទាំងតូចធំ មិនអោយរួបរុំសន្ដានទៅ ។
ទ្រង់ត្រាស់ដឹងឯងដោយប្រពៃ ឥតគ្រូដទៃប្រៀនប្រដៅ
ទ្រង់មានចរិយាឥតហ្មងសៅ ករុណាឆ្ពោះទៅសត្វគ្រប់គ្នា ។
និងបញ្ញាគុណចាក់ធ្លុះធ្លាយ ជ្រៅឆ្ងាយទូលាយអនន្ដា
ព្រះអង្គជាគ្រូក្នុងលោកា ឥតមានគ្រូណាប្រៀបផ្ទឹមបាន ។
ទ្រង់គង់ក្នុងវត្តវេឡុវ័ន ជាទីកលន្ទនិវាស្ថាន
ជិតក្រុងរាជគ្រឹះដែនបូរាណ ដែលប្រាកដមានក្នុងមគធា ។
ភិក្ខុអរហន្ដដ៏ពណ្ណរាយ ពាន់ពីររយឬាយហាសិបណា
ចូលទៅគង់គាល់នៅត្រៀបត្រា កបដោយនាថាដ៏ឧត្ដម ។
ហើយទើបព្រះអង្គទ្រង់សន្និបាត សម្ដែងឱវាទបាតិមោក្ខសម
ចំពោះភិក្ខុសង្ឃដ៏ឧត្ដម ដែលមកជួបជុំនៅពេលនោះ ។
ជាសាសនានៃព្រះពុទ្ធម្ចាស់ គ្រប់អង្គតែងត្រាស់ឥតមានមោះ
យ៉ាងខ្លីសង្ខេបល្មមពីរោះ ដោយគាថានោះតែបីបទ ។
ក្នុងថ្ងៃពេញបូណ៌មីមាឃា កបនក្ខត្ដាល្អប្រាកដ
ហើយប្រជុំភិក្ខុកំណត់ ទ្រង់សម្ដែងបទវិនយា ។

ជាច្បាប់សម្រាប់ភិក្ខុខ្ជី ពោលគឺបាលីបាតិមោក្ខា
មានអត្ថបរិសុទ្ធដ៏ថ្លៃថ្លា សូត្រថ្ងៃឧបោសថាតាមវេណី ។

មួយទៀតកាលអង្គព្រះសុគត សម្រេចឥរិយាបថក្រុងវេសាលី
មានភិក្ខុចោមរោមជាប្រក្រតី ទ្រង់ប្រាប់សេចក្ដីអោយដឹងដាន ។

ថានៅតែបីខែទៀតទេ ទ្រង់នឹងបែររេចូលនិព្វាន
បរិស័ទទាំងពួងយើងខ្ញុំមាន ក្ដីប្រាថ្នាបានទាន់ធម៌គ្រប់ ។

៧៥

| | |
|---|---|
| យើងខ្ញុំសូមលើកព្រះសម្ពុទ្ធ | និងសង្ឃជាបុត្រខីណាស្រព |
| និព្វានកន្លងយូរថ្ងៃយប់ | នឹកមិនមានឈប់ដោយជ្រះថ្លា ។ |
| យើងខ្ញុំបានដល់នក្ខត្តឫក្ស | មង្គលអ៊ឹកៈធឹកធំណាស់សា |
| បាននាំគ្នាធ្វើសក្ការា | ទៀនធូបជាអាទិ៍តាមប្រឹងប្រែង ។ |
| យើងខ្ញុំមានចិត្តត្រេកអរីករាយ | ជួបជុំខ្វល់ខ្វាយទីនេះឯង |
| ដើម្បីសក្ការៈតាក់តែង | បូជាកោតក្រែងដោយផ្ចិតផ្ចង់ ។ |
| សូមថ្វាយបង្គំសូមបូជា | ឆ្ពោះព្រះភគវាសាវ័កសង្ឃ |
| តាមកាលឆ្ពោះភក្ត្រនៃព្រះអង្គ | និព្វានយូរលង់នោះហើយក្តី ។ |
| កាលដែលសម្តែងព្រះបាតិមោក្ខ | ខែមាឃមានជោគបុណ្ណមី |
| ព្រះចន្ទចាំងចែងរឿងរង្សី | ឧបោសថពិសីបរិសុទ្ធា ។ |
| ដោយបុណ្យបូជាតាមសទ្ធា | សួស្តីសោភាមានគ្រប់គ្រា |
| សាសនាសាស្តាយើងរាល់គ្នា | ថ្កុំថ្កើងថិរាយូរអង្វែង ។ |

# វិធីសូត្រវិសាខបុណ្ណមីបូជា

## គាថាប្រារព្ធពិសាខបូជា (ថ្ងៃពេញបូណ៌មី)

វិសាខបុណ្ណមាយំ យោ ជាតោ អន្តិមជាតិយា
បត្តោ ច អភិសម្ពោធឹ អថោបិ បរិនិព្វុតោ ។
លោកេ អនុត្តរោ សត្ថា ទយាញាណន្នវាសយោ
នាយកោ មោក្ខមគ្គស្មឹ តិវិធត្ថូបទេសកោ ។
មហាការុណិកំ នាថំ មយន្តំ សរណំ គតា
អាមិសេហិ ច បូជេន្តា ធម្មេ ច បដិបត្តិយា ។
ឥមន្ទានិ សុនក្ខត្តំ អភិមង្គលសម្មតំ ។

## ប្រែពាក្យកាព្យ

វីអង្គសម្ពុទ្ធ ជាម្ចាស់ឯណា ប្រពៃថ្លៃថ្លា អស្ចារ្យក្នុងលោក
ក្នុងជាតិជាទី បំផុតឥតរក អ្នកណាមានជោគ ស្មើនឹងព្រះអង្គ ។
ដែលទ្រង់ប្រសូត នៅក្រោមដើមរាំង ជាអស្ចារ្យខ្លាំង ក្នុងលោកទាំងបី
ក្នុងថ្ងៃសុក្រជា ពារពេញបូណ៌មី ខែវិសាខនៃ រវាងឆ្នាំច ។
លុះព្រះជន្មម្ភៃ ប្រាំបួនហើយក៏ ទ្រង់យាងចេញចរ ទៅបព្វជ្ជា
កណ្តាលអាធ្រាត ថ្ងៃពេញបុណ្ណមា ខែអាសាធនា រវាងឆ្នាំថោះ ។
លុះព្រះជន្មសាម-សិបប្រាំទ្រង់ត្រាស់ ដឹងសព្វគ្មានខ្វះ ជាសព្វញ្ញូ
ក្នុងថ្ងៃពុធពិត ជាថ្ងៃពេញបូណ៌ ខែពិសាខោ នាឆ្នាំរកា ។
ហើយជាគ្រូធំ លើមនុស្សទេវតា "ឥតមានសាស្តា ដទៃផ្ទឹមបាន"
ទ្រង់មានករុណា និងបញ្ញាញាណ ជ្រាលជ្រៅដូចស្ពាន មហាសមុទ្ទ ។
និងអធ្យាស្រ័យ មិនរើសមុខមាត់ ទ្រង់យាងនាំសត្វ ក្នុងផ្លូវនិព្វាន
ហើយទ្រង់សម្តែង សេចក្តីទូន្មាន បីប្រការបាន គ្រប់ពួកបរិស័ទ ។

៧៧

លុះដល់ព្រះអង្គ ព្រះជន្មកំណត់ ប៉ែតសិបឆ្នាំគត់ ទ្រង់ចូលនិព្វាន
លើផែនថ្មធំ ឧត្តមក្សេមក្សាន្ត ក្រោមដើមរាំងដែន កុសិនារា ។
ក្នុងថ្ងៃអង្គារ ពារពេញបុណ្ណមា នៃវិសាខា រវាំងឆ្នាំម្សាញ់
យើងខ្ញុំទាំងឡាយ មិនមានកំណាញ់ ជឿស្មើអស់អញ ក្នុងការកុសល ។
សូមដល់ព្រះពុទ្ធ ព្រះអង្គតម្កល់ ព្រះទ័យខ្វាយខ្វល់ ករុណាដល់សត្វ
អង្គនោះថាជា ទីពឹងប្រាកដ ស្មើដោយជីវិត ឥតពឹងដទៃ ។
ហើយសូមបូជា ដោយគ្រឿងប្រពៃ តាមពាក្យបាលី ហៅថាអាមិស
និងដោយនូវ ធម្មបូជានេះ ប្រតិបត្តិមិនខុស ក្នុងព្រះធមិឡើយ ។
យើងខ្ញុំទាំងឡាយ ឱនកាយថ្វាយហើយ ចិត្តពុំកន្តើយ ក្រេបយកប្រយោជន៍
ចំពោះមគ្គផល ដល់ទៅបរលោក សូមឱ្យបានជោគ គ្រប់ជាតិទៅហោង ៕

# អធិដ្ឋានភ្នំខ្សាច់

**ឥមំ ខាលុកំ, ចូឡាមណីចេតិយំ, តាវតឹស ភវនេ អធិដ្ឋាម, នោ មាតាបិតុ, គរុអាទីនញ្ចេវ, មយ្ហញ្ច ទីឃរត្តំ, អត្ថាយ ហិតាយ សុខាយ ទុតិយម្បិ...។ តតិយម្បិ...។**

យើងខ្ញុំព្រះករុណាទាំងឡាយ, សូមតាំងសច្ចា, អធិដ្ឋានថា, នូវពំនូកខ្សាច់នេះ, ទុកហាក់ដូចជា, ព្រះចូឡាមណីចេតិយ, ស្ថិតនៅស្ថានតាវតិង្ស ។

បពិត្រព្រះចូឡាមណីចេតិយដ៏ចម្រើន, សូមព្រះអង្គ ព្រះមេត្តាទទួលយក, នូវគ្រឿងសក្ការៈទាំងឡាយ, មានទៀន ធូបភ្ញីផ្កា, និងទង់ជ្វាលាជាដើម, ដើម្បីជាប្រយោជន៍, ជាគុណ, និងសេចក្តីសុខ ដល់អ្នកដ៏មានគុណទាំងឡាយ, មានមាតាបិតា ជាដើមផង, ដល់យើងខ្ញុំព្រះករុណា ទាំងឡាយផង, អស់កាលជាអង្វែងទៅហោង ។

អស់វារៈពីរដងផង ។ អស់វារៈបីដងផង ៕

## ទេរមធុបាយាស

**មយំ ភន្តេ, មធុបាយាសំ ឥធានេត្វា, ពុទ្ធស្ស ទេម សាធុ ភន្តេ ពុទ្ធោ, ឥមំ មធុបាយាសំ បដិគណ្ហាតុ, អម្ហាកំ, ទីឃរត្តំ, អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ... ។ តតិយម្បិ... ។**

បពិត្រព្រះសម្មាសម្ពុទ្ធ ជាម្ចាស់ដ៏ចម្រើន, យើងខ្ញុំព្រះករុណាទាំងឡាយ, បានតាក់តែងហើយ នូវមធុបាយាស, ព្រមទាំងផលានុផលទាំងឡាយ, មកតម្កល់ទុកក្នុងទីនេះ ដើម្បីវេរថ្វាយដល់ព្រះសម្មាសម្ពុទ្ធ ព្រះបរមគ្រូជាអម្ចាស់ ។

បពិត្រព្រះសម្មាសម្ពុទ្ធ ជាម្ចាស់ដ៏ចម្រើន, សូមព្រះមេត្តាទទួលយកនូវមធុបាយាស, ព្រមទាំងផលានុផល ទាំងឡាយនេះ, របស់យើងខ្ញុំព្រះករុណាទាំងឡាយ, ដើម្បីជាប្រយោជន៍, ដើម្បីសេចក្តីសុខ, សេចក្តីចម្រើន, ដល់យើងខ្ញុំព្រះករុណាទាំងឡាយផង, ដល់ញាតិទាំងឡាយផង, អស់កាលជាអង្វែងទៅហោង ។

អស់វារៈពីរដងផង ។ អស់វារៈបីដងផង ។

# វេរកឋិនទាន

ឥមំ ភន្តេ, សបរិវារំ, កឋិនទុស្សំ(១) (ចីវរំ) សង្ឃស្ស, ឱណោជយាម, សាធុ នោ ភន្តេ សង្ឃោ ។

ឥមំ សបរិវារំ, កឋិនទុស្សំ, (កឋិនចីវរំ) បដិគ្គណ្ហាតុ, បដិគ្គហេត្វា ច, ឥមិនា ទុស្សេន, កឋិនំ (ចីវរេន) អត្ថរតុ, អម្ហាកញ្ច, មាតាបិតុអាទីនំ បេតកានំ, ញាតកានញ្ច, សព្វេសំយេវ, ទេវតានំ, ទីឃរត្តំ អត្ថាយ ហិតាយ, សុខាយ ។ ទុតិយម្បិ... ។ តតិយម្បិ... ។

បពិត្រព្រះសង្ឃជាម្ចាស់ដ៏ចម្រើន យើងខ្ញុំព្រះករុណាទាំងឡាយ សូមបង្អោនថ្វាយនូវសំពត់កឋិនទាន (ចីវរកឋិន) ព្រមទាំងបរិវារទាំងឡាយនេះ ចំពោះព្រះសង្ឃជាម្ចាស់ សូមព្រះសង្ឃជាម្ចាស់ មេត្តាអនុគ្រោះ ទទួលយកនូវសំពត់កឋិនទាន (ចីវរកឋិន) ព្រមទាំងវត្ថុដែលជាបរិវារ របស់យើងខ្ញុំព្រះករុណាទាំងឡាយ កាលទទួលរួចហើយ សូមនិមន្តក្រាលគ្រងនូវសំពត់កឋិននេះ(ចីវរកឋិន) ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់យើងខ្ញុំព្រះករុណាទាំងឡាយផង ដល់ញាតិទាំងឡាយមានមាតាបិតាជាដើមផង ដែលលះលោកនេះ ទៅកាន់បរលោកហើយក្តី ព្រមទាំងទេវតាទាំងឡាយទាំងពួងផង អស់កាលជាយូរអង្វែង តទៅខាងមុខនោះហោង ។

អស់វារៈពីរដងផង ។ អស់វារៈបីដងផង ។

---

(១) ត្រង់កណ្តាលវង់ក្រចកសម្រាប់ប្តូរពី កឋិនទុស្សំ (សំពត់ស) ទៅជា កឋិនចីវរំ (ចីវរ) បើកឋិនជាត្រៃចីវរ ។

## ទេវបង្សុកូលចីវរទាន

**ឥមានិ មយំ ភន្តេ, (បំសុកូលចីវរានិ)[១] សបរិវារានិ, ភិក្ខុសង្ឃស្ស, ឱណោជយាម, សាធុ នោ ភន្តេ ភិក្ខុសង្ឃោ, ឥមានិ បំសុកូលចីវរានិ, បដិគណ្ហាតុ អម្ហាកំ, ទីឃរត្តំ, អត្ថាយ ហិតាយ សុខាយ ។**

**ទុតិយម្បិ... ។ តតិយម្បិ... ។**

បពិត្រព្រះសង្ឃជាម្ចាស់ដ៏ចម្រើន យើងខ្ញុំព្រះករុណាទាំងឡាយ សូមបង្អោនថ្វាយនូវបង្សុកូលចីវរ[១] ព្រមទាំងបរិវារទាំងឡាយនេះ ប្រគេនចំពោះព្រះសង្ឃជាម្ចាស់ សូមព្រះសង្ឃជាម្ចាស់ មេត្តាអនុគ្រោះ ទទួលយកនូវបង្សុកូលចីវរ[១] ព្រមទាំងបរិវារនេះ របស់យើងខ្ញុំព្រះករុណាទាំងឡាយ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់យើងខ្ញុំព្រះករុណាទាំងឡាយ អស់កាលជាយូរអង្វែង តទៅខាងមុខនោះហោង ។

អស់វារៈពីរដងផង ។ អស់វារៈបីដងផង ៕

---

(១) ត្រង់កណ្តាលវង់ក្រចកសម្រាប់ប្តូរឈ្មោះនៃទាន ។

## ទេរចតុប្បច្ច័យជាសង្ឃទាន

**មយំ ភន្តេ, ឥមេ ចត្តារោ បច្ចយេ, ឥធានេត្វា សង្ឃស្ស ទេម, សាធុ នោ ភន្តេ សង្ឃស្ស, ឥមេ ចត្តារោ បច្ចយេ, បដិគណ្ហាតុ អម្ហាកំ, ទីឃរត្តំ, អត្ថាយ, ហិតាយ, សុខាយ ។**

**ទុតិយម្បិ.... ។ តតិយម្បិ... ។**

បពិត្រព្រះសង្ឃជាម្ចាស់ដ៏ចម្រើន, យើងខ្ញុំព្រះករុណាទាំងឡាយ, បាននាំមកហើយនូវបច្ច័យទាំងឡាយ ៤ នេះ, មកតម្កល់ទុកក្នុងទីនេះ, ហើយវេរប្រគេនដល់ព្រះសង្ឃជាម្ចាស់, បពិត្រព្រះសង្ឃជាម្ចាស់ដ៏ចម្រើន, សូមព្រះសង្ឃមេត្តាទទួលយក, នូវបច្ច័យទាំងឡាយ៤នេះ, របស់យើងខ្ញុំព្រះករុណាទាំងឡាយ, ដើម្បីជាប្រយោជន៍, ដើម្បីសេចក្តីសុខ, សេចក្តីចម្រើន, ដល់យើងខ្ញុំព្រះករុណាទាំងឡាយផង, ដល់ញាតិទាំងឡាយផង, អស់កាលជាអង្វែងទៅហោង ។

អស់វារៈពីរដងផង ។ អស់វារៈបីដងផង ៕

## ខេរផ្កាហិរញ្ញវត្ថុ

**មយំ ភន្តេ សទ្ធាបសន្នា ឥធ អារាមេ (សេនាសនករណត្ថាយ)[១] ឥមានិ ហិរញ្ញបុប្ផានិ ឥធានេត្វា សង្ឃស្ស បវារេម ។**

**សាធុ ភន្តេ សង្ឃោ វិនយានុរូបំ កប្បិយការកស្ស ហត្ថេ ឋបិតានិ ឥមានិ ហិរញ្ញបុប្ផានិ បដិគ្គណ្ហាតុ, មាតាបិតាទីនំ, គុណវន្តានញ្ចា, អម្ហាកញ្ចា, ទីឃរត្តំ, អត្ថាយ, ហិតាយ, សុខាយ ។**

**ទុតិយម្បិ... ។ តតិយម្បិ... ។**

## ប្រែថា

បពិត្រព្រះសង្ឃដ៏ចម្រើនអើយ យើងខ្ញុំទាំងឡាយមានសទ្ធាជ្រះថ្លា បាននាំមកនូវផ្កាហិរញ្ញវត្ថុទាំងឡាយនេះ សូមបវារណាចំពោះព្រះសង្ឃ (ដើម្បីកសាងសេនាសនៈ) ក្នុងវត្តនេះ ។

បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃទទួលដឹងនូវផ្កាហិរញ្ញវត្ថុទាំងឡាយនេះ ដែលយើងខ្ញុំទាំងឡាយ បានទុកដាក់ហើយក្នុងដៃនៃកប្បិយការកៈ ដ៏សមគួរដល់វិន័យ ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខគ្រប់ប្រការ ដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់យើងខ្ញុំទាំងឡាយផង អស់កាលជាយូរអង្វែងទៅហោង ៕

អស់វារៈពីរដងផង ។ អស់វារៈបីដងផង ។

---

(១) ត្រង់កណ្ដាលវង់ក្រចកសម្រាប់បញ្ចូលបាលីឈ្មោះវត្ថុដែលត្រូវវេរ ។

# បុណ្យកតញ្ញូ

## ពិធីសូមខមាទោស

**ឧបជ្ឈាយេ បមាទេន ទ្វារត្តយេន កតំ សព្វំ**

**អបរាធំ ខមថ នោ (ខេ ម្ហាក់៦១) ភន្តេ ។**

(សូត្របីដង)

## ថ្វាយគ្រឿងសក្ការៈបូជា

ទូលព្រះបង្គំ ខ្ញុំម្ចាស់ទាំងឡាយ ជាសិស្សានុសិស្ស ឧបាសក-ឧបាសិកា ទាំងបព្វជិត-គ្រហស្ថបានព្រមព្រៀងសាមគ្គី នាំមកហើយ នូវគ្រឿងសក្ការៈបូជាមានទៀនធូបភ្ញីផ្កាជាដើមចូលមកបូជាថ្វាយ **សម្តេចព្រះអគ្គិសិរីសុគន្ធាមហាសង្ឃរាជាធិបតី កិត្តិឧទ្ទេសបណ្ឌិត បួរ គ្រី សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា** នាបួក្សពារវេលាល្អ គឺថ្ងៃ..............................................

..........................................................................................................នេះ ។

សូមសម្តេចព្រះមហាសង្ឃរាជគ្រូជាអម្ចាស់ ព្រះមេត្តាទទួលយកនូវគ្រឿងសក្ការៈទាំងឡាយនេះ ដោយព្រះបរមរាជានុគ្រោះដ៏ខ្ពង់ខ្ពស់បំផុត ដើម្បីជាការសន្តោសដល់ទូលព្រះបង្គំ ខ្ញុំម្ចាស់ទាំងឡាយ ជាសិស្សានុសិស្ស ហើយនឹងដើម្បីជាប្រយោជន៍ ដល់ការប្រព្រឹត្តបដិបត្តិ ត្រឹមត្រូវតាមពុទ្ធមាគ៌ាតរៀងទៅ ។

ចត្តារោ ធម្មា វឌ្ឍន្តិ ធម៌បួនប្រការគឺៈ អាយុ ព្រះជន្មាវស្សាយឺនយូរវិសេស វណ្ណៈ ផូរផង់ថ្លៃថ្លា សុខៈ សួស្តីចម្រើនក្រៃ ពលៈ មាំមួនខ្លាំងក្លា ស្តេចគង់ចម្រើនក្នុងព្រះបវរពុទ្ធសាសនា ជានិច្ចនិរន្តរ៍ កុំបីជាប្រការដទៃឡើយ ។

## **ថ្វាយព្រះសុគន្ធវារី**

ថ្ងៃនេះជាថ្ងៃប្រកបដោយនក្ខត្តឫក្សសម័យ ត្រូវនឹងឫក្សពារវេលាល្អ សង្ឃសាមគ្គី ខាងក្នុងមានព្រះសង្ឃ ខាងក្រៅ មានពុទ្ធសាសនិកជនទាំងឡាយ ជាសក្ខីភាព ទើប ព្រមព្រៀងគ្នា រកបានមកហើយនូវព្រះគង្គាថ្លៃវិសេស ថ្វាយចំពោះ

**សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី កិត្តិឧទ្ទេសបណ្ឌិត បួរ គ្រី**

**សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា**

ស្រោចស្រប់ស្រង់ជម្រះព្រះអង្គ គង់ជាព្រះបរមសុខ ចម្រើនវិបុលសុខសព្វគ្រប់ប្រការ

ជាភិយ្យោភាព ។

**សិទ្ធិកម្មំ សិទ្ធិកិច្ចំ សិទ្ធិលាភោ ជយោនិច្ចំ ។**

**ជយតុភវំ ជយតុភវំ ជយតុភវំ ។**

**សាធុ! សាធុ! សាធុ! ។**

## ប្រកាសទេវតា

**ភោន្តោ ទេវសំឃាយោ អស្មិំ ឋានេ សមាគម្ម**
**ទីឃាយុកា សទា ហោន្តុ អម្ហេ រក្ខន្តុ សព្វទា ។**

បពិត្រពពួកទេវតាទាំងឡាយ សូមអញ្ជើញចូលមក សន្និបាតប្រជុំព្រម ក្នុងទីអាវាសវត្តនេះ សូមចម្រើននូវអាយុយឺនយូរវែងឆ្ងាយទៅ ស្ថិតនៅក្នុងទិព្វសម្បត្តិ ហើយសូមរក្សាយើងខ្ញុំទាំងឡាយ ឱ្យបានសេចក្តីសុខ សប្បាយសព្វកាលទាំងពួង សូមជួយអនុមោទនា ត្រេកអរនឹងកុសលផលបុណ្យ ដ្បិតយើងខ្ញុំទាំងឡាយ មានចិត្តជ្រះថ្លាប្រាថ្នាចង់ទំនុកបម្រុងព្រះពុទ្ធសាសនា ឱ្យថ្កើងរុងរឿងដរាបដល់ ៥០០០ ព្រះវស្សាប្រាថ្នាមគ្គផល ខ្វល់ខ្វាយចាយទ្រព្យ រណ្តាប់តាក់តែង រៀបចំនូវគ្រឿងសក្ការៈទាំងឡាយ មានទៀនធូបភ្ញីផ្កាជាដើម ថ្វាយចំពោះព្រះរតនត្រ័យ នៅក្នុងថ្ងៃបុណ្យ (...............) ហើយសូមឧទ្ទិសកុសលជូនដល់ទេវតាទាំងឡាយ មានព្រះឥន្ទព្រះព្រហ្មជាដើម បានកុសលផលបុណ្យ នេះឱ្យបានបរិបូរ ។

មួយវិញទៀត សូមឧទ្ទិសកុសល ដល់លោកអ្នកមានគុណទាំងឡាយ មានមាតាបិតាជាដើម ដែលធ្វើកាលកិរិយា ក្ស័យទៅហើយក្តី ដែលរស់នៅក្តី ក៏សូមឱ្យបានកុសលផលបុណ្យ ផ្សាយទៅឱ្យបរិបូរ មួយវិញទៀត ក្រែងជនទាំងឡាយ ដែលធ្វើកាលកិរិយា ក្ស័យទៅហើយ បានទៅកើត ក្នុងអបាយភូមិទាំង ៤ ទៅសោយទុក្ខវេទនាលំបាកក្នុងទីណា១ ក៏យើងខ្ញុំឧទ្ទិសកុសលផ្សាយទៅ សូមឱ្យរួចចាកទុក្ខទាំងពួង ហើយក៏សូមឱ្យទៅកើតជា (ទេវបុត្ត-ទេវធីតា) ម្យ៉ាងទៀត បើជនទាំងឡាយនោះមានកម្មជាទម្ងន់ ហើយផ្សាយកុសលទៅពុំដល់សោត ក៏សូមទេវតាដែលមាន ព្រះនេត្រទិព្វ-ព្រះកាណ៌ទិព្វ នាំកុសលទាំងអម្បាលនេះ ទៅជម្រាបឱ្យបានដឹងផង ឱ្យអនុមោទនា ត្រេកអរនឹងកុសល សម្គាល់ថាបីដូចជាកុសល គឺខ្លួនបានធ្វើដោយអំណាចកុសល ផលបុណ្យ ដែលយើងឧទ្ទិសបញ្ជូនទៅ ព្ធដ៏គ្រាឥឡូវនេះឯងហោង ៕

## អដ្ឋង្គិកមគ្គ ៨

អដ្ឋង្គិកមគ្គទាំងប្រាំបី ជាផ្លូវព្រះអរិយៈទាំងឡាយ
ដំណើរដ៏ល្អតែងនាំកាយ ទៅកាន់ប្រទ្បាយព្រះនិព្វាន ។
សម្មាទិដ្ឋិ ឃើញផ្លូវស្រេច ឃើញអរិយសច្ចទាំង៤មាន
ឃើញមែនឃើញពិតព្រះនិព្វាន ឃើញសុខផ្ទឹមគ្មានអស់ទុក្ខា ។
វិអង្គសម្មាសង្កប្បោនេះ តម្រិះដែលត្រិះត្រង់ឧស្សាហ៍
រារុញធុញសព្វក្តីប្រាថ្នា ចិន្តាចង់ចៀសចាកកាមគុណ ។
សម្មាវាចា ពោលពាក្យពិត សុចរិតឥតពោលមុសាធុន
មិនស័កមិនសៀតឆ្កៀតពាក្យធ្ងន់ ពាក្យណាជាគុណទើបចរចា ។
សម្មាកម្មន្តោធ្វើការត្រូវ ជាផ្លូវមេថុនមិនប្រាថ្នា
មិនលោភមិនលួចទ្រព្យអ្នកណា បាណា វៀរមិនសម្លាប់សត្វ ។
សម្មាអាជីវោ កាន់សុចរិត ចិញ្ចឹមជីវិតគិតប្រយ័ត្ន
មិនលក់មិនជួញមនុស្សនិងសត្វ បំបាត់ជំនួញ ៥ ប្រការ ។
សម្មាវាយាមោ ព្យាយាមត្រូវ ធ្វើត្រូវមិនឱ្យធ្លោយប្រាជ្ញា
ព្យាយាមរវាំងអកុសលា មិនឱ្យខ្លាំងក្លាកើតឡើងបាន ។
ព្យាយាមលះបាបដែលមានហើយ មិនធ្វើកន្តើយឱ្យរំខាន
រំលត់ឱ្យផុតចាកសន្តាន មិនឱ្យកើតបានក្តីវេទនា ។
ព្យាយាមញុំាងកុសលដែលមានពិត ឱ្យរីតចម្រើនកើនមហិមា
កុសលណាគ្មានកុំរួញរា ព្យាយាមពុះពារកុំបីស្តាយ ។
សម្មាសតិហប្ញទ័យនឹក ភាវនារំឭកក្នុងរាងកាយ
បញ្ញាពិចារណាឱ្យរឿយៗ ក្នុងចិត្តគិតព្រួយខ្លាចភយា ។
អនិច្ចំមិនទៀងរាល់រូបកាយ ទុក្ខំទាំងឡាយព្រោះតណ្ហា
ស្រឡាញ់ជាប់ចិត្តក្នុងរូបា ខន្ធប្រាំអនត្តាសង្ខារសូន្យ ។
សម្មាសមាធិ ធ្វើចិត្តត្រូវ ចិត្តតាំងខ្ជាប់នៅយ៉ាងមាំមួន
សមថវិបស្សនាបញ្ញាក្បួន ឯកកត្តាអស់ខ្លួននិព្វានហោង ៕

## រំឭកគុណមាតាបិតា ឧទ្ទិសផល

នមោ ខ្ញុំសូមនមស្ការ ឱនអង្គសិរសាថ្វាយបង្គំ
មាតាបិតាព្រះគុណធំ បុព្វការឧត្តមគ្មានអ្វីស្មើ ។
ឱះឱ! អ្នកម្តាយដ៏ស្នេហា លោកឪពុកណាំពីរអង្គា
ប្រឹងប្រែងខ្វល់ខ្វាយសព្វវេលា ថែទាំបុត្រភ្ញាយ៉ាងប្រពៃ ។
កាលនៅក្នុងគភ៌លោកមេត្តា ករុណាសន្តោសពន់ពេកក្រៃ
អត់ទ្រាំតស៊ូគ្រប់ខែថ្ងៃ កូនកើតចាកផ្ទៃនោះអ្នកម្តាយ ។
បីបមថ្នាក់ថ្នមលើឱរា វាចាផ្អែមល្ហែមចិត្តប្រណី
ស្រឡាញ់ខ្នាញ់បុត្រនៅតូចខ្ចី ថែមិនឱ្យភ័យដល់ពុំងារ ។
កាលកូននៅតូចលោកខ្វល់ខ្វាយ រកទ្រព្យទាំងឡាយយ៉ាងវេទនា
បានមកចិញ្ចឹមបុត្រស្ងួនភ្ញា បាត់ឃ្លានរងាបាត់ក្តីសោក ។
ទឹកដោះចំណីនូវអាហារ លោកតែងម្ទីម្នាស្ទុះទៅរក
បំបៅបញ្ចុកបុត្រពន្លក ឱ្យកូនបរិភោគបានសុខា ។
ជួនកូនស្រែកយំមានភយា អ្នកមិនរួញរាស្ទុះឆាប់រ៉ា
បីផងច្រៀងផងលួងកូនថា កូនលក់ទៅណាលើទ្រូងម្តាយ ។
ទឹកមាត់ទឹកមូត្រលាមកលាយ ក្លិនភាយអាក្រក់សៅហ្មងក្រៃ
អ្នកគ្មានញញើតចាប់ដោយដៃ ជម្រះបុត្រថ្លៃឥតជិនឆ្អន់ ។
អក្សរសិល្បសាស្ត្រលេខនព្វន្ត បង្ហាត់បុត្រមុនជានិរន្តរ៍
ជាបុព្វាចារ្យវិសេសពន់ នឹងថ្លែងអស់គុណលោកពុំបាន ។
ថ្ងៃនេះកូនសូមផ្គង់អញ្ជលី លើកហត្ថទាំងពីរបន្ទន់ប្រាណ
បង្គំព្រះព្រហ្មដ៏ក្សេមក្សាន្ត ទោសខុសប៉ុន្មានសូមប្រណី ។
បានខុសនូវកាយនូវវាចា នូវចិត្តក្តីណាវង្វេងក្រៃ
ពុំបានគោរពព្រះគុណថ្លៃ សូមលោកប្រណីអត់ទោសា ។

៨៩

ម៉្យាងទៀតកូនសូមឧទ្ទិសផល	វិសេសវិសាលនូវចេតនា
ទានសីលសមាធិកូនសទ្ធា	ជូនលោកទាំងពីរទីនេះហោង ។
សូមលោកសម្រេចតាមប្រាថ្នា	សម្បត្តិមនុស្សាសួគ៌ទិព្វផង
សម្បូរហូរហៀរជាចម្បង	សុខុមកន្លងឆ្លងត្រៃភព ។
មានអាយុវែងសម្បុរថ្លា	កម្លាំងខ្លាំងក្លាចិន្តាស្ងប់
មានសទ្ធាសីលសតិសព្វ	បញ្ញាអារ្យទ្រព្យនិព្វានហោង ៕

# វសន្តិលកា

# គោរពទន់សាសនា-បួងសួងសុំសន្តិភាព

(បទសរភញ្ញ)

## កំណាព្យពាក្យ ៧

១- សូមថ្វាយបង្គំព្រះសម្ពុទ្ធ ប្រសើរបំផុតក្នុងលោ-កា
ជាគ្រូនៃមនុស្សនិងទេព្តា ទ្រង់ត្រាស់ទេស្នាប្រដៅ-សត្វ ។

២- ចង្អុលឱ្យដើរផ្លូវក-ណ្តាល មាគ៌ាត្រកាលអាចក-ម្ចាត់
ទុក្ខភ័យចង្រៃអោយខ្ចាយ-បាត់ អាចកាត់សង្សារទុក្ខ-បាន ។

៣- សាសនាព្រះអង្គនៅសព្វ-ថ្ងៃ សត្វមាននិស្ស័យពីបុ-រាណ
ប្រឹងរៀនប្រឹងស្តាប់ចេះចាំ-បាន កាន់តាមលំអានបានក្តី-សុខ

៤- ឥតមានសុខណាស្មើក្តី-ស្ងប់ បញ្ចប់ត្រឹមសុខឃ្លាតចាក-ទុក្ខ
តាំងពីលោកនេះតទៅ-មុខ ក្តីសុខនឹងមានព្រោះធម៌-ស្ងប់។

៥- ខ្ញុំសូមបង្គំឆ្ពោះព្រះ-ធម៌ ព្រះសង្ឃបវរទាំងគ្រប់-សព្វ
រួមជាត្រៃរ័ត្នគួរគោ-រព ជាម្លប់ត្រជាក់នៃលោ-កា

៦- ព្រះរូបព្រះធាតុនៃព្រះ-ពុទ្ធ វិសុទ្ធតាងអង្គព្រះសា-ស្តា
សូមគុណត្រៃរ័ត្នជួយខេមរា ឱ្យបានសុខា តរៀងទៅ ។